ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>

# <u>នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី១៨)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង

លោក ម៉ាត្ទូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ ប៊េត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទួអាត ហ្វដ *(Mr. Stuart FORD)*

**មេធាវីការពារជនជាប់ចោទ កាំង ហ្កេក អ៊ាវ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យ៉ុង ផានិត

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទូត ហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រីអេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សីជំនាញ៖** លោក ក្រេក អេតឆេសាន់

សួរដោយ ចៅក្រម ស៊ីលយ៉ា ខាត់វ៉ាយថ៍ ផ្តើមពី........................................................ ទំព័រ ៦
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ផ្តើមពី ........................................................ ទំព័រ១០
សួរដោយ លោក អាឡិចសាន់ឌឺ ប៊ែត ផ្តើមពី ........................................................ ទំព័រ២២

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អាឡិចសាន់ឌឺ ប៊ែត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៍ | អង់គ្លេស |
| លោក ក្រេក អេតឆេសាន់ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |
| លោក ក្រេក អេតឆេសាន់ | អង់គ្លេស |
| លោកស្រី អេលីហ្សាប៊ែត វ៉ាបេសាន់ដ្រាតាណា | បារាំង |

# កិច្ចដំណើរការនីតិវិធី

[១០:៥៦:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។

អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី ព្រមទាំងសាធារណជនដែលបានចូលរួមនូវដំណើរការសវនាការនៅព្រឹកនេះបានជ្រាបថា ដំណើរការសវនាការរបស់សាលាដំបូងមិនអាចប្រព្រឹត្តទៅបានទេ ដោយមូលហេតុកិច្ចពិភាក្សាសម្រេចលើពាក្យសុំរបស់សហព្រះរាជអាជ្ញាក្នុងការណែនាំ ការអនុវត្តនូវវិធាន៨៧.២ និង៨៧.៣ នោះ មានលក្ខណៈស្មុគស្មាញ ហើយដោយសារស្ថានភាពនៃស្មុគស្មាញសំណុំរឿងនេះផង និងសំណុំរឿងផ្សេងៗទៀតដែលអង្គជំនុំជម្រះត្រូវពិចារណាហ្មត់ចត់ដោយផ្អែកលើមូលដ្ឋាននៃឯកសារនៃការអនុវត្តនានាព្រហ្មទណ្ឌអន្តរជាតិមួយចំនួនផង ហើយពិភាក្សាតាំងពីម្សិលមិញរហូតដល់ព្រឹកនេះ ក៏នៅមិនទាន់បានស្រេចទេ គឺយើងបានឯកភាពគ្នាជាគោលការណ៍ ប៉ុន្តែមិនអាចចេញជាសេចក្តីសម្រេចឲ្យបានច្បាស់លាស់ត្រឹមត្រូវបាន ។

ហេតុដូច្នេះ អង្គជំនុំជម្រះប្រកាសលើកដំណើរការសវនាការនៅព្រឹកនេះ ទៅបន្តនៅរសៀលវេលាម៉ោងមួយនិងសាមសិបនាទីរសៀល ។

អនុរក្សមន្ទីរឃុំឃាំង, នាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងមួយនិងសាមសិបនាទីរសៀលនេះ ។ ដោយឡែកមន្ត្រីតុលាការសម្របសម្រួលជាមួយនិងអ្នកជំនាញដើម្បីឲ្យគាត់បានសម្រាក ហើយនិងជម្រាបគាត់ឲ្យគាត់អញ្ជើញមកកាន់សាលសវនាការនៅម៉ោងមួយនិងសាមសិបនាទីរសៀល ។

*[សវនាការសម្រាកពីម៉ោង ១០:៥៨ នាទី ដល់ម៉ោង ១៣:៥០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ជាកិច្ចចាប់ផ្តើមដំណើរការសវនានៅរសៀលនេះ អង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីប្រកាស

នូវសេចក្ដីសម្រេចចំនួនពីរដូចតទៅ៖

ទីមួយ គឺសេចក្ដីសម្រេចផ្ទាល់មាត់ស្ដីពីការភាពអាចទទួលយកបាននូវឯកសារក្នុងសំណុំរឿងធ្វើជាភស្តុតាង។ អង្គជំនុំជម្រះសាលាដំបូងថ្មីៗនេះ បានទទួលសំណើពីសហព្រះរាជអាជ្ញាសុំប្រើឯកសារចំនួនបីជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ។ សំណើទាំងនោះដែលត្រូវបានជំទាស់ដោយសហមេធាវីការពារក្ដី គឺជាសំណើសុំប្រើប្រាស់ឯកសារដូចខាងក្រោមនេះ៖

ក) ចម្លើយរបស់សាក្សី បានស្ដាប់ចំនួនពីរនាក់ ដែលបានកត់ត្រាដោយតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលដែលចម្លើយនោះ--

**លោក ហ្រ្វង់ស្វ័រ រ៉ូ៖**

ខ្ញុំមានបញ្ហាបន្តិចដោយសារអ្នកបកប្រែ គាត់បកជាភាសាបារាំងមិនទាន់ សូមលោកប្រធានមានប្រសាសន៍យឺតៗបន្តិច ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីបានរំឭកខ្ញុំ ។ អ៊ីចឹង ខ្ញុំចាប់ផ្ដើមអាននូវសេចក្ដីសម្រេចនេះសាជាថ្មីឡើងវិញ ។

**សេចក្ដីសម្រេចផ្ទាល់មាត់ស្ដីពីភាពអាចទទួលយកបាននៃឯកសារក្នុងសំណុំរឿងធ្វើជាភស្តុតាង**

អង្គជំនុំជម្រះសាលាដំបូង ថ្មីៗនេះបានទទួលសំណើពីសហព្រះរាជអាជ្ញា សុំប្រើឯកសារចំនួនបីជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ។ សំណើទាំងនោះដែលត្រូវបានជំទាស់ដោយសហមេធាវីការពារក្ដី គឺជាសំណើសុំប្រើប្រាស់ឯកសារដូចខាងក្រោមនេះ៖

ក) ចម្លើយរបស់សាក្សីដែលបានស្ដាប់ចំនួនពីរនាក់ ដែលបានកត់ត្រាដោយតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាល ដែលចម្លើយនោះត្រូវបានដាក់នៅក្នុងសំណុំរឿងជាឯកសារលេខ D59/4 និង D59/12 ។

ខ) ចម្លើយរបស់ជនជាប់ចោទ ដែលកត់ត្រានៅក្នុងខែឧសភា ឆ្នាំ១៩៩៩ ដោយតំណាងឧត្ដមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHCHR) ដែលចម្លើយនោះ បានត្រូវដាក់ក្នុងសំណុំរឿងជាឯកសារ D9 ។ អង្គជំនុំជម្រះសាលាដំបូង ក៏បានទទួលសំណើបន្ថែមមួយទៀតរបស់សហព្រះរាជអាជ្ញា ដើម្បីសុំការអនុញ្ញាតប្រើប្រាស់ឯកសារលេខ 19/25 ដែលគេហៅថារបាយការណ៍ ឈឿន សុទ្ធី នៅចំពោះមុខអង្គជំនុំជម្រះ ។ សេចក្ដីសម្រេចលម្អិតជាលាយលក្ខណ៍អក្សរ

ដោយមានសំអាងហេតុស្តីពីបញ្ហាទាំងនេះត្រូវបានពិនិត្យរួចរាល់ហើយដោយអង្គជំនុំជម្រះសាលាដំបូង ហើយនិងត្រូវចេញនៅពេលការបកប្រែត្រូវបានបញ្ចប់ភ្លាម ។

[១៣:៥៥:៤៤]

សេចក្តីសម្រេចនេះត្រូវបានសង្ឃឹមថា នឹងចេញក្នុងពេលឆាប់ៗខាងមុខនេះ ។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះសាលាដំបូងអំពីសេចក្តីសម្រេចដោយផ្ទាល់មាត់ពាក់ព័ន្ធនឹងសំណើទាំងនេះដូចខាងក្រោម៖

អង្គជំនុំជម្រះសម្រេចទទួលសំណើរបស់មេធាវីការពារក្តី ទាក់ទងនឹងចម្លើយរបស់សាក្សីដែលបានទទួលមរណភាព គឺអត្ថបទពាក់ព័ន្ធដែលចេញផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam និងបទសម្ភាសន៍ដែលធ្វើដោយឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ UNHCHR ប៉ុន្តែមិនយកឯកសារទាំងនេះមកធ្វើជាភស្តុតាងទេ ផ្អែកតាមវិធាន៨៧.៣ នៃវិធានផ្ទៃក្នុង។

ទទួលសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាទាក់ទងនឹងរបាយការណ៍អំពី ឈឿន សុទ្ធី អនុញ្ញាតឲ្យលើកយកឯកសារនេះនៅចំពោះមុខអង្គជំនុំជម្រះដែលជាកម្មវត្ថុនៃការដេញដោលស្របតាមវិធាន៨៧.២ នៃវិធានផ្ទៃក្នុង ។

បង្គាប់ឲ្យការិយាល័យសហព្រះរាជអាជ្ញាផ្តល់របាយការណ៍ពី ឈឿន សុទ្ធី បកប្រែដែលជាសំណៅដើមដល់មេធាវីការពារក្តី ។ នេះជាសេចក្តីសម្រេចទីមួយរបស់សាលាដំបូងនៅរសៀលនេះ ។

តទៅនេះ អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសនូវសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដែលបានស្នើកាលពីម្សិលមិញ៖

ការិយាល័យសហព្រះរាជអាជ្ញាបានស្នើសុំការណែនាំពីអង្គជំនុំជម្រះសាលាដំបូងអំពីវិធីសាស្ត្រនៃការដាក់ឯកសារទាក់ទងទៅនឹងការធ្វើសក្ខីកម្មរបស់អ្នកជំនាញបណ្ឌិត ក្រេក អេតឆេសាន់ នៅចំពោះមុខអង្គជំនុំជម្រះ ។ ការិយាល័យសហព្រះរាជអាជ្ញាបានជូនដំណឹងអំពីបញ្ជីឯកសារដែលមានចំនួន១៤៨ ដែលមានលេខឯកសារ E55.1 ដែលការិយាល័យនេះមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ បញ្ជីឯកសារទាំងនោះ បានបង្ហាញនូវព័ត៌មានពេញលេញចំពោះឯកសារនីមួយៗ ដូចជា ស្ថានភាពនៃការបកប្រែភាសាដើម និងសេចក្តីសង្ខេបនៃឯកសារនីមួយៗ លើកលែងតែឯកសារលេខ៤ ។

[១៣:៥៨:៤៦]

អង្គជំនុំជម្រះសាលាដំបូង សូមថ្លែងអំណរគុណផងដែរ នូវកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញាក្នុងការជួយដល់អង្គជំនុំជម្រះ និងភាគីក្នុងការរៀបចំឯកសារដែល

មានចំនួនដ៏ច្រើននៅក្នុងសំណុំរឿង និងសូមជំរុញដល់ការិយាល័យនេះឲ្យបន្តនូវកិច្ចការរបស់ខ្លួនក្នុងការច្របាច់បញ្ចូលនូវឯកសារទាំងនេះតទៅទៀត ។

ជាការឆ្លើយតបទៅនឹងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ឥឡូវនេះ អង្គជំនុំជម្រះសាលាដំបូងដាក់ចេញនូវការណែនាំរបស់ខ្លួនទាក់ទងនឹងការជូនដំណឹងនេះដូចតទៅ៖

១) វិធាន៨៧.២ និង ៨៧.៣ គឺជាមូលដ្ឋានគ្រឹះក្នុងដំណើរការសវនាការប្រកបដោយភាពយុត្តិធម៌ ។ ឯកសារដែលភាគី ឬអង្គជំនុំជម្រះមានបំណងយកមកប្រើ ដើម្បីគាំទ្រដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវតែយកមកដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ហើយត្រូវបានអានទាំងមូល ឬត្រូវបានសង្ខេប មានតែឯកសារ ឬផ្នែកនៃឯកសារដែលបានយកមកដេញដោល នៅចំពោះមុខអង្គជំនុំជម្រះតាមវិធីនេះ ហើយដែលឯកសារនោះជាកម្មវត្ថុនៃការពិភាក្សាដេញដោលតែប៉ុណ្ណោះ ទើបត្រូវបានចាត់ទុកថា បានដេញដោលជាផ្លូវការនៅចំពោះមុខអង្គជំនុំជម្រះ ។

លក្ខខណ្ឌនៃវិធាន៨៧.២ ដែលថា ឯកសារណាមួយជាកម្មវត្ថុនៃការពិភាក្សា គឺត្រូវបានបំពេញទាំងស្រុងនៅពេលដែលមិនមានការជំទាស់ ។ មានតែផ្នែកនៃឯកសារដែលបានសង្ខេបនោះប៉ុណ្ណោះដែលត្រូវចាត់ទុកថា បានដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ។ ឧទាហរណ៍ ប្រសិនបើជំពូកណាមួយនៃសៀវភៅត្រូវបានសង្ខេប គឺមានតែផ្នែកនេះទេ ដែលត្រូវបានចាត់ទុកថា បានយកមកដេញដោល ប៉ុន្តែ ប្រសិនបើការពិភាក្សាលើឯកសារនោះហួសពីវិសាលភាពនៃការសង្ខេបបឋមនោះ អង្គជំនុំជម្រះអាចយកការពិភាក្សាទាំងមូលនោះមកធ្វើជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួនបាន ។ នៅពេលដែលឯកសារត្រូវបានយកមកដេញដោល ភាគីដែលបានបង្ហាញឯកសារនោះត្រូវបញ្ជាក់ថា តើខ្លួនសុំឲ្យមានការពិចារណាឯកសារទាំងមូល ឬក៏មិនពិចារណា ? ប្រសិនបើភាគីសុំបង្ហាញតែផ្នែកណាមួយនៃឯកសារឯកសារនោះត្រូវចង្អុលបង្ហាញអំពីផ្នែកដែលពាក់ព័ន្ធនោះ ។ នៅពេលដែលឯកសារណាមួយ ដាក់នៅចំពោះមុខអង្គជំនុំជម្រះ ភាគីមានសិទ្ធិក្នុងជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារនោះដោយបញ្ជាក់នូវមូលហេតុសមស្រប ។

[១៤:០២:៣៥]

ភាគីក៏មានសិទ្ធិផងដែរនូវការស្នើសុំ ព័ត៌មានបន្ថែម ឬការបញ្ជាក់ណាមួយទាក់ទងនឹងឯកសារដែលភាគីណាមួយមានបំណងដាក់ជូននៅចំពោះមុខតុលាការ ។ ជារួម បញ្ជីឯកសារដែលបានដាក់បញ្ចូលគ្នាក្នុងឯកសារ E55 គឺមិនមានភាពគ្រប់គ្រាន់សម្រាប់គោលបំណងនៃវិធាន៨៧ ក្នុងការចាត់ទុកជា

ឯកសារ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនោះ ទេ ។ ឯកសារនីមួយៗត្រូវតែបានសង្ខេបដើម្បីឲ្យភាគីនិងអង្គជំនុំជម្រះមានឱកាសវាយតម្លៃលើឯកសារ នោះ ។

២) ជាគោលការណ៍ ឯកសារដែលបានសង្ខេបនោះ គួរតែមានជាភាសាខ្មែរ ពីព្រោះភាសាខ្មែរគឺជាភាសាផ្លូវការរបស់តុលាការ និងជនជាប់ចោទ ។

៣) សូមរំឭកដល់ភាគីទាំងអស់ថា មាត្រា១៥ នៃអនុសញ្ញាស្តីពីការហាមឃាត់ការធ្វើទារុណកម្ម បានចែងថា "ភាគីរដ្ឋត្រូវធានីថា ឯកសាររបាយការណ៍ទាំងឡាយដែលបង្កើតឡើងបានមកពីអំពើទារុណកម្មមិនត្រូវយកមកសំអាង ជាធាតុនៃភស្តុតាងក្នុងនីតិវិធីណាមួយឡើយ ដែលបានធ្វើឡើងដោយសារការធ្វើទារុណកម្ម ។ លើកលែងតែឯកសាររាយការណ៍នោះត្រូវបានធ្វើឡើងសម្រាប់ជាភស្តុតាងប្រឆាំងនឹងជនជាប់ចោទនៃអំពើទារុណកម្ម ។

នេះជាសេចក្តីសម្រេច ហើយសូមជូននាទីនេះទៅ លោកស្រីចៅក្រម ដើម្បីបន្ថែម ។

សូមអញ្ជើញលោកស្រី ។

**លោកស្រី ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ សូមធ្វើការកែសម្រួលតូចមួយទៅលើសេចក្តីសម្រេចដែលទើបតែបានអានដោយលោកប្រធានអម្បាញ់មិញនេះ ។ កំហុសនេះ គឺកើតមានឡើងដោយសារមានឯកសារមួយដែលអ្នកបកប្រែគាត់មាន ទីមួយ គឺទាក់ទងទៅនឹងវិធាន៨៧ គឺថាវិធាន៨៧ គឺជាវិធានសំខាន់ណាស់ ។ ហើយគឺថាយើងមិនសំដៅតែទៅលើវិធានតូច អនុវិធាន៨៧.៣ តែប៉ុណ្ណោះទេ គឺយើងយោងទៅលើវិធាន៨៧ ទាំងមូល ។

សូមអរគុណលោកប្រធាន ។

[១៤:០៥:៥០]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត មុននឹងប្រគល់វេទិកានេះទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមជូននាទីនេះទៅលោកស្រីចៅក្រម ខាត់វ៉ាយថ៍ ដើម្បីមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងលោកបណ្ឌិត ក្រេកអេតឆេសាន់ ដែលជាអ្នកជំនាញ ។

សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកបណ្ឌិត អេតឆេសាន់ តើលោកអាចធ្វើសេចក្តីសង្ខេបទៅលើរបាយការណ៍របស់លោកបានទេ? របាយការណ៍ទស្សនទានរបស់លោកស្តីអំពីរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ ដែលពេលនុំងឯង គឺឯកសារនេះមិនទាន់បានជាឯកសារដែលត្រូវបានតាំងសំណួរដល់លោកនៅឡើយទេ ។ មានន័យថា ខ្ញុំត្រូវការតែសេចក្តីសង្ខេបអំពីទស្សនទានពីខាងដើមតែប៉ុណ្ណោះ។

**ឆ៖** ពិតណាស់ខ្ញុំអាចធ្វើបាន ។ អ៊ីចឹងនៅក្នុងដំណើរការនេះដែរ ខ្ញុំក៏ចង់ធ្វើការបញ្ជាក់ដែរថាតើចំណុចខ្លះដែលខ្ញុំបានធ្វើការពិភាក្សាពីមុន ហើយដែលថាមិនបានគ្រប់គ្រាន់នោះ សូមឱ្យខ្ញុំដឹងផង ។

ឯកសារនេះ គឺជាឯកសារដែលមាននៅក្នុងសំណុំរឿង ហើយបានរៀបរាប់ជាផ្លូវការអំពីរបាយ-ការណ៍ជាផ្លូវការអំពីការវិភាគ ។ ជាការលើកឡើងវិញ ដើម្បីកំណត់ហេតុអំពីអ្វីដែលយើងបានពិភាក្សាគ្នាកាលពីម្សិលមិញ ឯកសារដែលមាននៅក្នុងសំណុំរឿងហ្នឹង គឺឯកសារលេខ D2.15,66 ហើយលេខ *ERN* ជាភាសាអង់គ្លេស គឺលេខ 00146822 រហូតដល់លេខ 00146887 ។ អត្ថន័យនៃក្នុងអត្ថបទហ្នឹងគឺមានជា៣៧ទំព័រ ហើយចែកអំពីទស្សនទាន អំពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយនេះ គឺជាចំណងជើងដែលយើងបានប្រើជាទូទៅសម្រាប់កំណត់ហេតុ ។

ផ្នែកដំបូងនៃរបាយការណ៍នេះ គឺរៀបរាប់អំពីមន្ទីរមជ្ឈិម អំពីតំបន់ អំពីភូមិភាគ និងស្រុករបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលយើងបានរៀបរាប់ពីមុនមកហើយ ។

ផ្នែកទីពីរនៃរបាយការណ៍នេះ មានចំណងជើងថា "គណៈអចិន្ត្រៃយ៍" យើងក៏បានពិភាក្សាគ្នារួចហើយទៅលើផ្នែកមួយនេះ ។ ហើយផ្នែកមួយចំនួនទៀតនៃរបាយការណ៍នេះរួមបញ្ចូលទាក់ទងទៅនឹងបុគ្គលិក ការចាត់តាំងជាដើម ត្រូវបានពិភាក្សា និងសមាសភាពរបស់គណៈអចិន្ត្រៃយ៍ ។ ផ្នែកការទទួលខុសត្រូវផ្នែកសន្តិសុខរបស់គណៈអចិន្ត្រៃយ៍ផងដែរ ។ ទាក់ទងទៅនឹងគោលនយោបាយសេដ្ឋកិច្ចរបស់គណៈអចិន្ត្រៃយ៍ ហើយនិងការទំនាក់ទំនង ហើយនិងសមត្ថភាពធ្វើការទំនាក់ទំនងរបស់គណៈអចិន្ត្រៃយ៍។

[១៤:១០:០៨]

ផ្នែកបន្ទាប់មកទៀតនៃរបាយការណ៍នេះ គឺមានចំណងជើងថា "ភូមិភាគ" ។ ដំបូងចាប់ផ្តើមឡើងដោយធ្វើការរៀបរាប់អំពីការទទួលខុសត្រូវរបស់គណៈភូមិភាគ ដូចដែលបានរៀបរាប់នៅក្នុងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលរួមបញ្ចូលទាំងតារាងបង្ហាញអំពីថ្នាក់ដឹកនាំរបស់ភូមិភាគរបស់កម្ពុជាប្រជាធិបតេយ្យ ។ ហើយបន្ទាប់មកទៀតផ្នែកហ្នឹងក៏ធ្វើការរៀបរាប់ផងដែរអំពីបុគ្គលិក អំពីការចាត់

តាំង និងអំពីការទទួលខុសត្រូវរបស់គណៈស្រុក អំពីការទទួលខុសត្រូវផ្នែកសន្តិសុខរបស់គណៈស្រុក (សូមទោស គឺរបស់គណៈភូមិភាគ) និងការទទួលខុសត្រូវផ្នែកសេដ្ឋកិច្ចរបស់គណៈភូមិភាគ ដែលរួមបញ្ចូលទាំងការទទួលយកឲ្យបាននូវសមិទ្ធផលបីតោនក្នុងមួយហិចតា និងការកសាងទំនប់ទឹកផ្សេងៗទៀត ។

ផ្នែកនៃរបាយការណ៍នេះដែរក៏រួមបញ្ចប់អំពីការពិនិត្យទៅលើការទំនាក់ទំនងនៃថ្នាក់ដឹកនាំភូមិភាគទៅកាន់ថ្នាក់ដឹកនាំជាន់លើ ទៅគណៈអចិន្ត្រៃយ៍ ហើយនិងទៅថ្នាក់ជាន់ក្រោមផងដែរ ដែលជាថ្នាក់ស្រុក ហើយនិងថ្នាក់ភូមិ ថ្នាក់ឃុំ ។

ផ្នែកបន្ទាប់មកទៀតនៃរបាយការណ៍នេះមានចំណងជើងថា “តំបន់” ចាប់ផ្ដើមដោយធ្វើការរៀបរាប់អំពីការទទួលខុសត្រូវជាផ្លូវការរបស់គណៈតំបន់ ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា ។ ដោយរួមបញ្ចូលទាំងការបង្ហាញអំពីថ្នាក់ដឹកនាំតំបន់ ដោយបង្ហាញអំពីថ្នាក់ដឹកនាំនៅតាមតំបន់ផ្សេងៗ នៅតាមតំបន់បូព៌ា ។ ផ្នែកមួយនេះនៃរបាយការណ៍ក៏បានបន្តដោយធ្វើការពិភាក្សាអំពីបុគ្គលិក អំពីការចាត់តាំងដែលទាក់ទងទៅនឹងគណៈតំបន់ ហើយយើងក៏បានពិភាក្សាផ្នែកខ្លះនៃផ្នែកនេះរួចទៅហើយ ។

បន្ទាប់មកទៀត គឺមានការរៀបរាប់អំពីការទទួលខុសត្រូវផ្នែកសេដ្ឋកិច្ចរបស់គណៈតំបន់ ជាពិសេសគឺការទទួលយកឲ្យបានលទ្ធផលបីតោនក្នុងមួយហិចតា ។ ហើយនិងការផ្ដោតអារម្មណ៍តែមួយទៅលើការកសាងទំនប់ ហើយនិងព្រែក ហើយនិងបណ្ដាញផ្លូវទឹកជាច្រើនទៀត ។ ផ្នែកនៃរបាយការណ៍ដែរក៏មានរៀបរាប់អំពីការពិភាក្សាអំពីទំនាក់ទំនងរវាងគណៈតំបន់ ដែលរួមបញ្ចូលទាំងការទំនាក់ទនងទៅថ្នាក់លើ និងទៅថ្នាក់ភូមិភាគជាដើម ហើយនិងការធ្វើការទាក់ទងទៅថ្នាក់ក្រោម គឺមានន័យថាទៅថ្នាក់ស្រុក ហើយនិងទៅថ្នាក់ឃុំ ។

[១៤:១៣:១៩]

ផ្នែកបន្ទាប់មកទៀតនៃរបាយការណ៍នេះគឺរៀបរាប់អំពីស្រុក គឺអំពីទស្សនទាន អំពីការទទួលខុសត្រូវរបស់គណៈស្រុក ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជា ដោយរួមបញ្ចូលទាំងការបង្ហាញអំពីថ្នាក់ដឹកនាំស្រុក និងតារាងដឹកនាំ តារាងរចនាសម្ព័ន្ធ ដោយបង្ហាញអំពីស្រុក មេដឹកនាំ និងគឺនៅភូមិភាគពាយព្យ គឺនៅតំបន់៥ ។

ហើយបន្ទាប់មកទៀត នៅក្នុងរបាយការណ៍នោះ គឺមានរៀបរាប់អំពីផ្នែកបុគ្គលិក ហើយនិង

បញ្ហាផ្សេងៗទៀតទាក់ទងនឹងសន្តិសុខ ទាក់ទងទៅនឹងគណៈស្រុក ។ ឯកសារនេះបន្តពិភាក្សាអំពីការទទួលខុសត្រូវផ្នែកសន្តិសុខនៅក្នុងថ្នាក់ស្រុករបស់បក្ស ។ ហើយឯកសារនេះបន្តនិយាយអំពីការទទួលខុសត្រូវអំពីបញ្ហាសេដ្ឋកិច្ចនៅក្នុងថ្នាក់ស្រុករបស់បក្សផងដែរ ។

នៅក្នុងផ្នែកបន្ទាប់នៃរបាយការណ៍មួយនេះ ដែលមានចំណងជើងថា "ឃុំ-សហករណ៍ និងសាខាផ្សេងៗ" ។ ផ្នែកនេះ គឺចាប់ផ្តើមដោយលើកឡើង និងពន្យល់អំពីសាខាដែលស្ថិតនៅក្រោមជួរក្រោមបំផុតនៅក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា ។ ផ្នែកនេះបន្តធ្វើការពិភាក្សាអំពីបុគ្គលិក និងអង្គការចាត់តាំង ហើយនិងសាខារបស់បក្ស ។ ហើយបន្ទាប់មកពិភាក្សាអំពីការទទួលខុសត្រូវផ្នែកសន្តិសុខនៅក្នុងថ្នាក់សាខា ហើយនិងការទទួលខុសត្រូវផ្នែកសេដ្ឋកិច្ចផងដែរ ។ ហើយមាននៅក្នុងនេះបានធ្វើការសន្និដ្ឋានអំពីការទំនាក់ទំនងនៅក្នុងថ្នាក់សាខា ហើយថាតើថ្នាក់សាខាធ្វើការទាក់ទងទៅថ្នាក់លើតាមតំបន់ តាមភូមិភាគ និងស្រុកតាមរបៀបណា?

ផ្នែកបន្ទាប់ទៀតនៅក្នុងរបាយការណ៍នេះ និយាយអំពីបញ្ហាគណៈយោធាមជ្ឈិមបក្ស ។ វាបានពិពណ៌នាអំពីការរៀបចំតាមរដ្ឋធម្មនុញ្ញនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយបានពិពណ៌នាដោយសង្ខេបអំពីបទប្បញ្ញត្តិនិងលក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជាចំពោះជួរយោធា ។ ហើយបន្តពិភាក្សាពិពណ៌នាទៅលើសមាសភាពនៃគណៈយោធា នៃគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា របស់កម្ពុជាប្រជាធិប-តេយ្យ ។ ហើយនៅផ្នែកដែលនៅសល់ គឺពិភាក្សាអំពីអ្វីដែលយើងដឹងថា ជាសកម្មភាព និងគោលនយោបាយរបស់គណៈមជ្ឈិមនៃជួរយោធា ។

ផ្នែកបន្ទាប់ទៀត និយាយអំពីអគ្គសេនាធិការនៃទ័ពបដិវត្តន៍ យោធាបដិវត្តន៍កម្ពុជា ។ ផ្នែកនេះគឺមានតារាងចាត់តាំង មានរចនាសម្ព័ន្ធចាត់តាំងដែលយើងដឹងអំពីរចនាសម្ព័ន្ធរបស់អគ្គសេនាធិការ ។ នៅក្នុងផ្នែកនៃរបាយការណ៍នេះ គឺធ្វើការសរុបទៅលើអំពីការទំនាក់ទំនង និងរបៀបនៃការទំនាក់ទំនងរបស់អគ្គសេនាធិការនៅក្នុងបដិវត្តន៍របស់កម្ពុជា ។

ហើយផ្នែកបន្ទាប់ទៀត បាននិយាយអំពីជួរថ្នាក់ក្រោមរបស់យោធា ដែលមានចំណងជើងថា "មេបញ្ជាការយោធាកងពលធំ និងមេបញ្ជាការកងវរសេនាធំឯករាជ្យ" ហើយបាននិយាយអំពីផ្នែកទាក់ទងទៅនឹងបុគ្គលិក និងអង្គការចាត់តាំង ។ ហើយក៏បានរួមបញ្ចូលអំពីតារាងចាត់តាំងដែលបានរៀបរាប់អំពីវរសេនាធំឯករាជ្យ និងកងពលនៃកងទ័ពបដិវត្តន៍កម្ពុជានៅដើមឆ្នាំ១៩៧៧ ។

នៅក្នុងផ្នែក នៅក្នុងរបាយការណ៍ក៏បានបន្តនិយាយអំពីការទទួលខុសត្រូវសន្តិសុខផ្ទៃក្នុង និង

ខាងក្រៅរបស់កងទ័ពបដិវត្តន៍កម្ពុជា ហើយក៏បានលើកឡើងអំពីការទទួលខុសត្រូវផ្នែកសេដ្ឋកិច្ចផងដែរ ចំពោះកងទ័ពរបស់កងទ័ពបដិវត្តន៍កម្ពុជា ។ ផ្នែកនេះបានធ្វើការសន្និដ្ឋានដោយលើកឡើងអំពីការទំនាក់ទំនងនៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា ។

ផ្នែកបន្ទាប់ទៀតនៃរបាយការណ៍នេះ គឺនិយាយអំពីក្រសួងនានា ។ នៅក្នុងផ្នែកនេះគឺបានលើកឡើងអំពីគណៈប្រតិបត្តិនៃកម្ពុជាប្រជាធិបតេយ្យ ដែលយើងហៅថារដ្ឋាភិបាល ឬក៏អង្គនីតិប្រតិបត្តិ និងរដ្ឋបាល ។ ហើយនៅក្នុងនេះយើងឃើញមានការពិពណ៌នាអំពីការចាត់តាំងផ្សេងៗ ។ ចំពោះការទទួលខុសត្រូវនៅក្នុងជួររដ្ឋាភិបាល ហើយយើងឃើញមានដ្យាក្រាម ដែលវាជារចនាសម្ព័ន្ធរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

ផ្នែកមួយនេះ គឺបានធ្វើការសន្និដ្ឋានដោយលើកឡើងការវិភាគពិស្តារ ថាតើមានអ្វីកើតឡើងនៅក្នុងក្រសួងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ហើយបានលើកឡើងអំពីការិយាធិបតេយ្យនៅក្នុងជួរបក្សនៅក្នុងក្រសួងទាំងអស់នោះ ។ ផ្នែកមួយនេះគឺបានធ្វើការបញ្ចប់ដោយពិភាក្សាទៅលើការទំនាក់ទំនងនៅក្នុងជួរក្រសួង ហើយនិងការទំនាក់ទំនងរវាងក្រសួង និងថ្នាក់លើរបស់គណៈមជ្ឈិមបក្ស ។

[១៤:១៩:៥៨]

ហើយនៅក្នុងចំណុចចុងក្រោយ របាយការណ៍មួយនេះ គឺបានធ្វើការសន្និដ្ឋានបញ្ចប់ដោយធ្វើការសង្ខេបពិភាក្សាយ៉ាងខ្លី ទៅលើការទទួលខុសត្រូវតាមរដ្ឋធម្មនុញ្ញរបស់សភាតំណាងប្រជាជន ។ របាយ-ការណ៍បានបន្តដោយមានឧបសម្ព័ន្ធ “ក” នៅក្នុងនោះមានជើងទំព័រ លេខយោង៣៥៥ ហើយលើកឡើងនូវលេខយោងចំនួនច្រើន ដែលខ្ញុំយកមកសំអាង ហើយខ្ញុំដឹងថាខាងសហព្រះរាជអាជ្ញាចង់លើកឡើងអំពីឯកសារយោងចំនួន១៤៨ទាំងអស់នោះ ហើយយើងក៏ឃើញមានឧបសម្ព័ន្ធចំពោះរបាយការណ៍នេះផងដែរ ដែលនៅក្នុងនោះ មានប្រភពឯកសារផ្សេងៗ ដែលខ្ញុំយោង ហើយបានយកមកធ្វើជាមូល-ដ្ឋាននៅក្នុងរបាយការណ៍របស់ខ្ញុំ ។ លោកស្រីចៅក្រមយល់ថា វាគ្រប់គ្រាន់ហើយឬនៅ ចំពោះសេចក្តីសង្ខេបរបស់ខ្ញុំលើរបាយការណ៍មួយនេះ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

អរគុណច្រើន វាមានប្រយោជន៍ណាស់ចំពោះការសង្ខេបនេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីហ្វ្រង់ស្វ័រ រូ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោកប្រធានជាគោរព! លោកស្នើសុំខាងមេធាវីការពារក្តីឲ្យបង្ហាញអំពីជំហររបស់ខ្លួនចំពោះឯកសារទាំងឡាយដែលសហព្រះរាជអាជ្ញាបានចែកជូនភាគីកាលពីម្សិលមិញពេលថ្ងៃ ។ ប្រហែលពេលនេះ ជាពេលដែលសមស្របចំពោះយើងខ្ញុំក្នុងការដាក់ជូននូវសេចក្តីសន្និដ្ឋាន ។ ចំណុចដែលសំខាន់នោះលោក អេតផេសាន់ ទើបតែចង្អុលបង្ហាញអំម្បាញ់មិញនេះថា យើងមានឧបសម្ព័ន្ធ “ក”ភ្ជាប់ទៅនឹងរបាយការណ៍មួយនេះ ហើយលោកបណ្ឌិតក៏បាននិយាយផងដែរថា មានឯកសារបន្ថែមចំនួនពីរផ្សេងទៀត ។ ដូច្នេះ វាហាក់ដូចជាបង្ហាញថា ខ្ញុំនិយាយនេះក្នុងលក្ខខណ្ឌតែប៉ុណ្ណោះ ។ ហើយវាហាក់ដូចជាមានឧបសម្ព័ន្ធ “ខ” និង “គ”ផងដែរ តាមអ្វីដែលគាត់លើកឡើង ។ ជាការសោកស្តាយខាងមេធាវីការពារក្តី មិនទទួលបានការបកប្រែនូវឧបសម្ព័ន្ធ “ខ” ឬក៏ “គ” នោះទេ ។

បន្ទាប់ពីធ្វើការស្រាវជ្រាវនៅ កន្លែងទីមួយចំនួន ហើយវាជាការចំណាយពេលមួយរបស់យើងខ្ញុំ ហើយយើងក៏បានយល់ឃើញថា លេខយោងទៅរកឯកសារពីរចុងក្រោយ ដែលលោកបណ្ឌិតបានលើកឡើង ដែលមាននៅក្នុងបញ្ជីនៅព្រឹក ការចែកជូនកាលពីព្រឹកមិញ គឺលេខ៣៩ និង៣០ ។ គឺលេខនេះវាមានរៀបចំនៅក្នុងឧបសម្ព័ន្ធ “គ” ហើយមិនដែលបានបញ្ជូនមកខាងមេធាវីការពារក្តី ជាភាសាបារាំងនោះទេ ។

[១៤:២៤:១៦]

ដូច្នេះ នេះជាមូលហេតុដែលយើងខ្ញុំមិនអាចស្វែងរកឯកសារ និងលេខយោងចំពោះឯកសារទាំងអស់នោះបានយ៉ាងជាក់ច្បាស់នោះ ។ ឯកសារនេះមិនបានបញ្ចូល ចាត់ថ្នាក់នៅក្នុងប្រព័ន្ធ ហ្សាយឡេបនោះទេ ។ ដែលអ្នកជំនាញបានបញ្ជាក់ថា វាមានឧបសម្ព័ន្ធ “គ”ចំពោះរបាយការណ៍របស់គាត់ ខាងមេធាវីការពារក្តីយល់ឃើញថា វាជាការសោកស្តាយ ដោយសារយើងមិនទទួលបានឯកសារបកប្រែចំពោះឧបសម្ព័ន្ធ “ខ” ឬ“គ” ជាភាសាបារាំង ។ ដូច្នេះហើយចំណុចនេះ បើសិនជាយើងទទួលបាន វាអាចជួយសន្សំពេលរបស់យើងខ្ញុំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សាង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ជាក់លាក់ចំពោះឯកសារទាំងនេះ ខ្ញុំកត់សម្គាល់ឃើញថា ចំពោះឯកសារលេខ៣០ វាមាន

ឯកសារសំដៅដើមជាភាសាខ្មែរ ហើយហាក់ដូចជាបង្ហាញថា វាជាការសង្ខេបនៅក្នុងភាសាអង់គ្លេស ហើយអត់មានឯកសារនុ៎ង ជាភាសាបារាំងនោះទេ ។ តើចំណុចនេះត្រឹមត្រូវដែរឬទេ នៅអ្វីដែលខ្ញុំលើកឡើង? ហើយបន្ថែមទៅលើចំណុចនេះទៀត ថាតើលោកចង់យករបាយការណ៍របស់លោកដោយផ្អែកទៅលើសេចក្តីសង្ខេប ឬក៏យ៉ាងម៉េច? ហើយលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ថាបុគ្គលណាជាអ្នករៀបចំរបាយការណ៍សង្ខេប ដែលលោកយកមកធ្វើជាបង្អែកនុ៎ង និងយោងនោះ?

**លោក ក្រេក អេតធេសាន់៖**

**ឆ៖** បាទ លោកចៅក្រម! មានឯកសារមួយចំនួនដែលខ្ញុំយោងនៅក្នុងឯកសារការវិភាគរបស់ខ្ញុំ គឺឯកសារទាក់ទងទៅនឹងការបកប្រែនោះ គឺថាមិនទាន់មាននៅឡើយទេ ចំពោះការបកប្រែ ហើយចំពោះឯកសារលេខ៣០ ដែលលោកចៅក្រមកំពុងតែនិយាយអំពីនោះ គឺចម្លើយសារភាពនៅស-២១ របស់ ខុំ ជុំ ។ ប្រសិនបើសិនជាខ្ញុំលើកឡើងមិនខុសទេនោះ គឺថាឯកសារនេះរៀបចំដោយលោកបណ្ឌិតស្ទីវវិនហេតឌ័រ ដែលជាអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។

[១៤:២៧:៣១]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកទើបតែលើកឡើងយោងទៅដល់ឯកសារសារភាពលេខ៣០ ប្រសិនបើយើងនិយាយយោងទៅដល់ឯកសារនេះ គឺឯកសារ៣០នោះ វាជាតេឡេក្រាម មិនមែនជាចម្លើយសារភាពទេ ។ តើអ្វីដែលខ្ញុំនិយាយនោះត្រឹមត្រូវដែរឬទេ?

ប្រហែលលោកយោងលើឯកសារ៣០ ដែលវាភ្ជាប់ទៅនឹងឯកសារហ្នឹង ឬក៏យ៉ាងម៉េច? គឺខ្ញុំចង់និយាយបញ្ជាក់ឲ្យច្បាស់ថា យើងនិយាយផ្តោតលើឯកសារតែមួយ មិនមែនផ្តោតលើឯកសារខុសគ្នា ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់សួរទៅខាងការិយាល័យសហព្រះរាជអាជ្ញាម្តង ។

បញ្ជីដែលផ្តល់ជូនមកអង្គសវនាការ និងភាគី ថាតើបញ្ជីនេះ គឺវាមានលេខលំដាប់ដូចគ្នា ដូចដែលឯកសារដែលវាមានដាក់បញ្ចូលនៅក្នុងឧបសម្ព័ន្ធ “គ” ឬក៏វាមិនតាមលំដាប់ដូចគ្នានោះទេ? តើវាមានភាពខុសគ្នា ឬក៏ខុសគ្នាចំពោះលេខលំដាប់ទាំងអស់ហ្នឹង?

**លោក អាឡិចសាន់ឌឺ បែត៖**

សូមអរគុណលោកចៅក្រម ចំពោះការតាំងសំណួរ ។ បញ្ហានេះវាហាក់ដូចជាស្មុគស្មាញ

ដោយសារយើងឃើញមានបញ្ជីចំនួនពីរ ដែលមានចំណងជើងថា ឧបសម្ព័ន្ធ “គ” ទាំងពីរ ។ នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ “គ” គឺមានឯកសារយ៉ាងច្រើនដែលវាពាក់ព័ន្ធទៅនឹងអង្គហេតុយ៉ាងច្រើនឥតគណនា ។ ហើយឧបសម្ព័ន្ធ “គ” ដែលវានៅខាងចុងរបាយការណ៍របស់លោក ក្រេក អេតឆេសាន់ គឺវាជាឯកសារមួយខុសពីនុំង ហើយវាហាក់ដូចជាធ្វើឲ្យយើងយល់ច្រឡំ ដោយសារវាមានភាពដូចគ្នា ។ ឧបសម្ព័ន្ធ “គ” ភ្ជាប់ទៅនឹងឯកសាររបាយការណ៍របស់លោក ក្រេក អេតឆេសាន់ គឺមានបញ្ជីអំពីឯកសារចំនួន៦០ ។ ហើយឯកសារទាំង៦០នោះ គឺរៀបរាប់នៅក្នុងតារាងដែលយើងខ្ញុំបានផ្តល់ជូនអង្គសវនាការ ។ គឺតារាងដែលមានឯកសារចំនួន១៤៨ ទាំងអស់នេះ ខ្ញុំសូមឲ្យលេខសម្គាល់ឯកសារមុន គឺឯកសារនេះលេខE55.1 ឯកសារចំនួន៦០ ដែលផ្តល់ជូនដោយលោក ក្រេក អេតឆេសាន់ ដែលមាននៅក្នុងឧបសម្ព័ន្ធ “គ” យើងអាចរកឃើញ ប្រសិនបើយើងមើលនៅក្នុងជួរទីពីរនៃឯកសារE55.1 ហើយប្រសិនបើយើងមើលទៅក្រោម នៅក្នុងឯកសារទីមួយ គឺបញ្ជីនៃសំណុំរឿង IS ឧបសម្ព័ន្ធ “គ” ។ តារាងបន្ទាប់ គឺឯកសារ ២.១ នោះគឺជាឯកសារទាក់ទងទៅនឹងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ហើយប្រសិនបើយើងមើលចុះក្រោមទៅដល់លេខ២ គឺវាដូចគ្នាដដែល ។ ទីបី ខាងក្រោមនុំង គឺដូចគ្នាដដែល គឺឯកសារទាក់ទងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ហើយឯកសារលេខ៤,៥,៦,៧ គឺមានការរៀបរាប់អំពីលេខសំណុំរឿង D2.15 ហើយឯកសារយោង គឺD2.5 ឧបសម្ព័ន្ធ២ ដែលវាភ្ជាប់ទៅនឹងឧបសម្ព័ន្ធរបស់លោក ក្រេក អេតឆេសាន់ ហើយខ្ញុំហាក់ដូចជា វាយល់ឃើញថា វាមានភាពស្មុគស្មាញ និងយល់ច្រឡំ ហើយវាមានភាពច្រឡំដោយសារតែដំណើរការ ដែលថា ឯកសារទាំងពីរនោះ គឺបានដាក់ចូលនៅក្នុងសំណុំរឿងជាប្រព័ន្ធអេឡិចត្រូនិច នៅក្នុងសំណុំរឿង ហើយខ្ញុំនឹងធ្វើការពន្យល់តាមអ្វី ដែលខ្ញុំអាចធ្វើទៅបានចំពោះឯកសារនេះ ដើម្បីឲ្យអង្គសវនាការធ្វើការស្វែងយល់ចំពោះឯកសារទាំងពីរនោះ ។ ទៅតាមការយល់ដឹងរបស់ខ្ញុំនុំង គឺថាទោះបីជាផ្នែកគ្រប់គ្រងរបស់តុលាការមានជាឯកសារ ជាច្បាប់រឹងក៏ដោយ នូវឯកសារទាំង៦០ នោះរបស់លោក អេតឆេសាន់ ដែលមាននៅក្នុងឧបសម្ព័ន្ធ “គ”របស់គាត់ ។ គឺពួកគាត់មិនបានទទួលឧបសម្ព័ន្ធ “គ” សម្រាប់លេខយោងនីមួយៗនៃឯកសារទាំង៦០នោះទេ ហើយជាបច្ច័យអាក្រក់នោះ គឺថាក្នុងការដើម្បីរកបាននូវឯកសារទាំងនោះនៅក្នុងប្រព័ន្ធ *ហ្សាយឡូប* ជាប្រព័ន្ធអេឡិចត្រូនិចនោះ គឺយើងត្រូវទៅរកមើលនៅក្នុងឧបសម្ព័ន្ធ “គ” នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរហើយស្ថិតនៅខាងក្រោមបទសម្ភាសន៍សាក្សី ហើយបន្ទាប់មកទៀតនៅខាងក្រោមហ្វូលឌ័រមួយទៀត គឺសម្ភាសសាក្សី ហើយគឺមាននៅក្នុងឯកសារពី១៨ ទៅ៨៣ ។

[១៤:៣៣:១៧]

ខាងសហព្រះរាជអាជ្ញាពុំបានដឹងថា តើហេតុបានជាផ្នែកគ្រប់គ្រងតុលាការធ្វើអ្វីតាមប្រព័ន្ធនេះទេ? យើងព្យាយាមរកបញ្ជាក់ឲ្យបានច្បាស់ទៅលើបញ្ហានេះ ពីព្រោះដូចជាខ្ញុំបានពន្យល់អ៊ីចឹង គឺដូចជាធ្វើឲ្យភាន់ច្រឡំដល់ភាគីពាក់ព័ន្ធទាំងអស់ ។ ហើយនេះមិនមែនជាអ្វីដែលខាងសហព្រះរាជអាជ្ញាយើងធ្វើទេ ពីព្រោះបញ្ហានេះ ជាបញ្ហាលំបាកណាស់ទាក់ទងទៅនឹងប្រព័ន្ធលេខនេះ ។ ក៏ប៉ុន្តែ ចម្លើយដ៏ខ្លីទៅលើសំណួររបស់លោកចៅក្រម គឺថាឯកសារ E55.1 គឺជាឯកសារគាំទ្រទៅលើកំណត់ហេតុនៃការវិភាគរបស់លោក អេតធេសាន់ ហើយពិតជាមានឧបសម្ព័ន្ធ “គ” ដែលមានឯកសារចំនួន៦០នៅទីនោះ ។ ប៉ុន្តែដើម្បីស្វែងរក គឺត្រូវមើលទៅលើកូឡោនទីពីរ ដើម្បីយកលេខយោង គឺD2.5 ឧបសម្ព័ន្ធ “គ” ឯកសារ១,២,៣,៤,៥,៦...។ល។

ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំបានលើកឡើងនុ៎ង អាចជួយបានទៅលើដំណើរដ៏ស្មុគស្មាញ ថាតើហេតុអ្វីបានជាឯកសារហ្នឹង វាពិបាកសម្រាប់ឯកសារ សម្រាប់ភាគីពាក់ព័ន្ធនានាក្នុងការរកនោះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ។

[១៤:៣៤:៥៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមានការបារម្ភខ្លះនៅពេលនេះ ពីព្រោះនេះខ្ញុំគិតថាភាគីផ្សេងៗ ក៏មានការបារម្ភដូចខ្ញុំដែរ ។ នៅពេលដែលយើងយោងឯកសារនៅក្នុងអង្គសវនាការ ហើយនៅពេលដែលឯកសារនោះត្រូវបានធ្វើសេចក្ដីសង្ខេប គឺថាយើងអាចចាត់ទុកថា ឯកសារនោះត្រូវបានបញ្ចូលនៅក្នុងអង្គសវនាការ ។

ដូច្នេះវាជាការចាំបាច់ណាស់ដែលថា យើងត្រូវមានការយល់ដឹងឲ្យបានច្បាស់លាស់ តើឯកសារណាដែលយើងនិយាយអំពីនោះ? យើងក៏ត្រូវមានការគិតផងដែរអំពីធាតុដើមនៃឯកសារនោះ ហើយអំពីការបកប្រែឯកសារនោះ តើវាដល់ដំណាក់កាលណាហើយ? ដូច្នេះដើម្បីធ្វើការអង្កេត ឬធ្វើការបញ្ជាក់ឲ្យច្បាស់លាស់អំពីការទទួលយកបាននូវឯកសារនោះ យើងត្រូវមានចំណុចអស់ទាំងហ្នឹង ។

អ៊ីចឹងខ្ញុំយល់ថា វាពិបាកបន្តិចមានស្មុគស្មាញនឹងបញ្ហានេះ ហើយអ្វីដែលខ្ញុំចង់បាននោះ គឺខ្ញុំចង់ឲ្យភាគីណាមួយដែលមានបំណងប្រាថ្នាចង់ដាក់ឯកសារណាមួយ ។ ខ្ញុំចង់ឲ្យពួកគេមានលេខយោងឲ្យបានច្បាស់លាស់ ហើយនិងផ្ដល់តារាងដែលជាអត្ថប្រយោជន៍សម្រាប់យើងទាំងអស់ ។ ហើយខ្ញុំចង់ឲ្យ

មានលេខយោងទាក់ទងទៅនឹងតារាងនោះ ដែលមានឯកសារណាមួយជាក់លាក់នៅទីនោះ ។ ដូច្នេះ គឺយើងអាចពិនិត្យមើលឃើញថា ចំណុចនេះអាចសម្រួលដល់កិច្ចការរបស់យើងគ្រប់ៗគ្នា ហើយដើម្បីធានាឲ្យបាន ឃើញថា មានការពិភាក្សាដេញដោលច្បាស់លាស់មែននោះ ។ ហើយខ្ញុំសូមនិយាយថា ខ្ញុំដូចជាការច្រឡំបន្តិចនៅទីនេះ ទាក់ទងទៅនឹងឯកសារដែលបានយោងដោយខាងមេធាវីការពារក្តីនោះ ។ អ៊ីចឹងថាតើឯកសារនោះ ជាឯកសារមានលេខយោងប៉ុន្មានដែរ នៅក្នុងបញ្ជីរបស់លោកហ្នឹង លោកមេធាវីការពារក្តីដែលលោកបានលើកឡើងនោះ? តើលោកអាចប្រាប់បានទេ? ឯកសារណាដែលជាឯកសារដែលលោកចង់លើកឡើងនោះ?

[១៤:៣៧:០៧]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ខ្ញុំមិនដឹងថាតើខាងមេធាវីការពារក្តី គាត់និយាយអំពីឯកសារ៣០នៅក្នុងតារាង E55.1 ឬក៏អត់ទេ? ដែលតាមគាត់យល់ថាន៎ុង គឺជាចម្លើយសារភាព ឬមួយក៏គាត់និយាយអំពីឯកសារ៣០ដែលជាលេខរៀងនៅក្នុងបញ្ជីឯកសារលេខ៣០ នោះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

កាលពីម្សិលមិញ អង្គសវនាការបានស្នើមេធាវីការពារក្តីឲ្យផ្តល់សេចក្តីអង្កេតរបស់ខ្លួនទាក់ទងទៅនឹងឯកសារចុងក្រោយចំនួនពីរដែលមាននៅក្នុងបញ្ជី ដែលខាងសហព្រះរាជអាជ្ញាបានបែងចែកដល់ភាគីពាក់ព័ន្ធទាំងអស់ កាលពីម្សិលមិញ ។ ហើយនៅខាងចុងនៃ*លីស* នោះ នៃបញ្ជីនោះ គឺមានឯកសារចំនួនពីរ ។ បាទឯកសារចុងក្រោយចំនួនពីរនោះ ដែលខ្ញុំបានលើកឡើងនោះ គឺមានជាលេខ IS ឧបសម្ព័ន្ធ “គ” D2.15 ឧបសម្ព័ន្ធ “គ” លេខ៣៩ ហើយនិងឯកសារទីពីរគឺឯកសារ D2.15 ឧបសម្ព័ន្ធ “គ” លេខ៣០ ហើយកាលពីម្សិលមិញលោកស្រីចៅក្រម ខាតរាយថ៍ បានសួរថា តើការអង្កេតរបស់យើងទាក់ទងទៅនឹងឯកសារអ្វីនោះ គឺទាក់ទងនឹងឯកសារទាំងពីរនេះ ។ ហើយអ្វីដែលខ្ញុំយល់នៅពេលនេះ គឺថាលោកស្រីបានសួរខ្ញុំឲ្យបញ្ជាក់ថា តើទាំងពីរន៎ុងមាននៅក្នុងតារាង E55 ដែរឬទេ? គឺ E55.1 នោះដែរឬទេ? បាទ តើអ្វីដែលខ្ញុំនិយាយនេះច្បាស់លាស់ឬទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំគិតថា ខ្ញុំរកឃើញឯកសារមួយក្នុងចំណោមឯកសារទាំងពីរនេះ ។ អ៊ីចឹងទាក់ទងទៅនឹងឯកសារ D2.15 ឧបសម្ព័ន្ធ “គ” លេខ៣០ មើលទៅ គឺថាឯកសារន៎ុងគឺលេខ ១១១២ ក្នុងបញ្ជី ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ពិតណាស់បាទ គឺជាឯកសារនុ៎ងហើយ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ៊ីចឹងខ្ញុំមិនដឹងថា តើលេខយោងដែលទាក់ទងទៅនឹងឧបសម្ព័ន្ធលេខ៣៩នោះ គឺជាឯកសារអ្វីទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកបណ្ឌិត ក្រេក អេតឆេសាន់ ចង់មានយោបល់អ្វី? សូមអញ្ជើញ ។

[១៤:៤១:៣៥]

**លោក ក្រេក អេតឆេសាន់៖**

បាទ, លោកប្រធាន ខ្ញុំប្រហែលជាអាចផ្តល់ការបញ្ជាក់ខ្លះទាក់ទងទៅនឹងបញ្ហានេះ ។

ឯកសារដែលមេធាវីការពារក្តីលើកឡើងមកនិយាយនោះ គឺដែលមានលេខ៣៩ នោះ គឺជាចម្លើយសារភាពនៅស-២១ របស់ ចាន់ សម ហៅ កង ចាប ហៅ សែ ។

នៅក្នុងតារាងបញ្ជីឯកសារដែលខាងសហព្រះរាជអាជ្ញាបានធ្វើការថែងចាយនោះ ក៏មានលេខយោងទៅនឹងចម្លើយសារភាពនៅ ស-២១ របស់ ចាន់ សម ហៅ កង ចាប ហៅ សែ នេះដែរ ។

ខ្ញុំគិតថា ឯកសារទាំងពីរនេះ គឺជាឯកសារតែមួយ គឺមានន័យថាជាឯកសារ៣១ នៅលើបញ្ជីនៃឯកសារដែលខាងការិយាល័យសហព្រះរាជអាជ្ញាបានផ្តល់ជូននោះ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

ត្រឹមត្រូវហើយ ។ អ៊ីចឹងបើក្នុងករណីហ្នឹង គឺថា វាមិនស៊ីគ្នាទៅនឹងអ្វីដែលសហសេរិកគាត់បាននិយាយ ហើយបានប្រាប់យើងកាលពីមុននោះ ទាក់ទងទៅនឹងឯកសារចំនួន៦០ នៅក្នុងឧបសម្ព័ន្ធ “គ” នៃរបាយការណ៍របស់លោក អេតឆេសាន់ ដែលត្រូវបានបញ្ចូលទៅក្នុងតារាងដែលបានលើកឡើងថាឯកសារ D2.15 នោះ ពីព្រោះនៅខាងក្រោមបញ្ជីលេខឯកសារលេខ៣១ នោះ គឺខ្ញុំអត់មានឃើញនិយាយយោងអំពីអ្វីទេ ។ អត់មានយោងទៅលើឯកសាររបស់លោក អេតឆេសាន់ ទេ ហើយលើសពីនេះទៀតនោះ ហើយអ្វីដែលធ្វើឲ្យខ្ញុំកាន់តែបារម្ភនោះ គឺថាបើសិនជាថា ឥឡូវឯកសារណាត្រូវដាក់បញ្ចូលក្នុង *ហ្សាយឡេប* នៅពេលនេះ ហើយបើសិនជាយើងយកលេខ ERN ដែលទាក់ទងទៅនឹងឯកសារលេខ៣១ នៅក្នុងតារាងនោះ ដែលនៅក្នុងតារាងនោះ គឺបង្ហាញថា នោះគឺជាឯកសារដែលជាចម្លើយសារភាពថ្ងៃ២៥ ខែតុលា ឆ្នាំ៧៨ ។ ប៉ុន្តែ នៅពេលដែលយើងចូលទៅ *ហ្សាយឡេប* ហើយ

ប្រើលេខយោងដូចគ្នានោះ ពេលនោះគឺមានការបង្ហាញអំពីចម្លើយសារភាពនៅថ្ងៃ១០ ខែកញ្ញា ឆ្នាំ៧៨ ទៅវិញ មានន័យថា ឯកសារទាំងពីរនេះ គឺមិនមែនជាឯកសារតែមួយនោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកបណ្ឌិត ។

[១៤:៤៤:៤៤]

**លោក ក្រេក អេតធេសាន់៖**

លោកប្រធាន, ខ្ញុំមិនអាចបញ្ជាក់ធ្វើការបង្ហាញ ថាតើភាពខុសគ្នាពីឯកសារនេះយ៉ាងម៉េចទេទៅលើឯកសារដែលខាងមេធាវីការពារក្ដីបានលើកឡើងនោះ គឺថាខ្ញុំនឹងធ្វើការអង្កេតទៅលើរបាយការណ៍របស់ខ្ញុំនេះ ហើយនឹងពិនិត្យមើលទៅលើចម្លើយសារភាពនៅស-២១ នេះថា លោកអាចលោកអាចបញ្ជាក់អំពីចំណុចនេះបាន ។

នៅក្នុងចម្លើយសារភាពភាគច្រើនដែលខ្ញុំបានសម្គាល់ឃើញ គឺថាមានការចុះបរិច្ឆេទផ្សេងៗគ្នាជាច្រើន ។ ជួនកាលមានការចុះបរិច្ឆេទនៅសន្លឹកទីមួយ ហើយបន្ទាប់មកទៀតមានការចុះបរិច្ឆេទផ្សេងៗគ្នាសូម្បីតែនៅលើសន្លឹកទីមួយក៏ដោយ ។ ជួនកាលនៅតាមផ្នែកផ្សេងៗនៅខាងក្នុងហ្នឹងក៏មានការចុះការបរិច្ឆេទផ្សេងៗគ្នាដែរ អាចជាថ្ងៃខែនៅចុងបញ្ចប់នៃចម្លើយសារភាពក៏មានដែរ ដែលខុសគ្នាពី ដែលផ្សេងគ្នាពីរការបរិច្ឆេទនៅសន្លឹកដំបូងនៃចម្លើយសារភាព ហើយនៅពេលដែលអ្នកដែលបញ្ចូលឯកសារនោះនៅក្នុងប្រព័ន្ធ គឺពិបាកក្នុងការកំណត់ថា តើឯកសារហ្នឹងត្រូវដាក់យកទៅតាមការបរិច្ឆេទមួយណា? ដូច្នេះ វាមិនមែនជាការចាំបាច់ដែលថា ឯកសារនេះវាផ្សេងគ្នានោះទេ ដោយបើសិនជាយើងគ្រាន់តែពិនិត្យមើលតែទៅលើការបរិច្ឆេទផ្សេងគ្នានៃឯកសារនោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ជាថ្មីម្ដងទៀត សម្រាប់ធ្វើបញ្ជាក់ឲ្យបានច្បាស់លាស់ ខ្ញុំចង់ដឹងថា តើអ្វីទៅដែលយើងត្រូវចាត់ទុកក្នុងការបញ្ចូលនៅក្នុងអង្គសវនាការ? តើយើងយោងទៅលើលេខ ERN របស់ឯកសារដើម ឬមួយក៏យ៉ាងម៉េច? បើតាមខ្ញុំគិតថា ឯកសារហ្នឹង គឺរួមបញ្ចូលទាំង១៥០ទំព័រនៅក្នុងនោះ គឺមានចំនួន ១៥៣ ទំព័រ ហើយយើងមានសេចក្ដីសង្ខេបនៃឯកសារនេះ ។ ហើយតាមខ្ញុំដឹង គឺថាមានសេចក្ដីសង្ខេបហ្នឹង

គឺមាន១២ទំព័រ ប៉ុន្តែយើងមិនមានជាភាសាបារាំងទេ ។

អ៊ីចឹងតើអ្វីទៅជាឯកសារដែលយើងត្រូវពិចារណាថា ត្រូវយកមកបញ្ចូលនៅក្នុងអង្គសវនាការនេះ? តើយើងនិយាយអំពីសេចក្ដីសង្ខេប ឬក៏និយាយអំពីចម្លើយសារភាពនៅស-២១? អ៊ីចឹងខ្ញុំចង់ឲ្យធ្វើការបញ្ជាក់ឲ្យបានច្បាស់ទៅលើចំណុចនេះ ប្រហែលជាលោក អេតឆេសាន់ អាចមកបង្ហាញបញ្ជាក់អំពីចំណុចនេះ យើងនិយាយអំពីភាពពេញលេញនៃឯកសារនោះ ឬមួយក៏អាស្រ័យទៅលើសេចក្ដីសង្ខេបនៃឯកសារនោះ?

[១៤:៤៧:៤៥]

**លោក ក្រេក អេតឆេសាន់៖**

សូមអរគុណលោកចៅក្រម ។ នៅក្នុងករណីជាច្រើន ខ្ញុំធ្វើការជាមួយអ្នកឯកទេសខាងភាសារបស់យើងដោយពិនិត្យមើលទៅលើឯកសារភាសាដើមជាភាសាខ្មែរ ដែលជាចម្លើយសារភាពនោះ ហើយដើម្បីពិនិត្យមើល ថាតើអត្ថបទ ឬក៏លក្ខខណ្ឌណាដែលមានជាចំណុចគួរឲ្យចាប់អារម្មណ៍ ដើម្បីការវិភាគរបស់យើងនោះ ។ ហើយជាទូទៅ គឺសេចក្ដីសង្ខេបនៃការវិភាគជាភាសាអង់គ្លេស គឺមានព័ត៌-មានចាំបាច់គ្រប់គ្រាន់ដើម្បីឲ្យខ្ញុំធ្វើការវិភាគផ្ទាល់ខ្លួនរបស់ខ្ញុំ ។

ដូច្នេះ ខ្ញុំសូមធ្វើសំណើថា គឺធ្វើសេចក្ដីសង្ខេបជាភាសាអង់គ្លេស ហើយនិងច្បាប់ដើមជាភាសាខ្មែរគួរតែត្រូវយកមកពិចារណា ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកស្រីចៅក្រម ខាតរាយច៍ ។

[១៤:៥២:២២]

**ចៅក្រម ស៊ីលយ៉ា ខាតរ៉ាយច៍៖**

សូមអរគុណ លោកប្រធាន ។

លោកប្រធាន បានណែនាំខ្ញុំឲ្យធ្វើការអញ្ជើញសហព្រះរាជអាជ្ញាឲ្យធ្វើការចាប់ផ្ដើមសំណួររបស់លោកទៅលើសាក្សីអ្នកជំនាញ លោកបណ្ឌិត អេតឆេសាន់ ។ លោកប្រធាន គាត់សុំធ្វើការថ្លែងអំណរគុណដល់ភាគីពាក់ព័ន្ធនានា ដើម្បីផ្ដល់ ដើម្បីជួយក្នុងការយល់ដឹងអំពីលេខយោងទៅលើឯកសារនានា ។ ហើយក៏សុំរំឭកទៅដល់ភាគីពាក់ព័ន្ធទាំងអស់ផងដែរថា ប្រសិនបើភាគីណាមួយមានការបារម្ភទាក់ទង

ទៅនឹងឯកសារណាមួយ ដែលខាងសហព្រះរាជអាជ្ញា ឬក៏ភាគីណាមួយមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះ ។ ហើយការបារម្ភហ្នឹង គឺថាអាចនឹងត្រូវបានលើកឡើងភ្លាមៗដើម្បីឲ្យអង្គជំនុំជម្រះនៅធ្វើសេចក្តីសម្រេចចិត្ត ។ តើៗមានអ្វីដែលលោកប្រធានចង់បន្ថែមទៀតទេ?

**ប្រធានអង្គជំនុំ៖**

មិនមានអីទេ ។ សូមអញ្ជើញ ។

អញ្ជើញសហព្រះរាជ តំណាងសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

អរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព!

[១៤:៥៣:៥៧]

**ប្រធានអង្គជំនុំ៖**

ឈប់ៗ ។ អញ្ជើញលោកមេធាវី ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

អរគុណលោកប្រធាន ។ ខ្ញុំសុំការអនុញ្ញាតធ្វើការស្នើសុំមួយដើម្បីយើងអាចបន្តទៅមុខបាន ។ យើងនៅក្នុងនេះ គឺនៅក្នុងការជំនុំជម្រះដែលជនជាប់ចោទ គាត់បានធ្វើការសារភាព និងទទួលយកអង្គហេតុមួយចំនួនដាក់បន្ទុកលើខ្លួន ។ ដូច្នេះ ថាតើយើងអាចស្នើសុំឲ្យការិយាល័យសហព្រះរាជអាជ្ញាឲ្យផ្តោតទៅលើ ផ្តោតជាចម្បងនោះទៅលើអង្គហេតុទាំងឡាយណា ដែលយើងកំពុងតែធ្វើការពិភាក្សាដេញដោល ហើយសុំឲ្យខាងព្រះរាជអាជ្ញានោះធ្វើការបង្ហាញឯកសារបី ឬក៏បួន ទាក់ទងទៅនឹងអង្គហេតុទាំងអស់នេះ ។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ជាទូទៅវាទាមទារលក្ខខណ្ឌថា ចម្លើយ ឬក៏ឯកសារទាំងឡាយត្រូវតែបញ្ចូលគ្នាយ៉ាងហោចណាស់ជាឯកសារមួយ ឬក៏ឯកសារមួយទៀត ។ ចំពោះខ្ញុំ ប្រសិនបើខាងការិយាល័យសហព្រះរាជអាជ្ញានឹងផ្តោតទៅលើ ផ្តល់ជូនឯកសារបី ឬបួន ជូនយើងខ្ញុំដែលឯកសារទាំងអស់នោះពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលជំទាស់ដោយជនជាប់ចោទនោះ នៅពេលនោះគឺយើងអាចនឹងចំណាយពេលនឹងកើនពេលកាន់តែច្រើន ។ ហើយអង្គហេតុនោះ គឺវាអាចមានដីកាធ្វើការតវ៉ា ដូច្នេះហើយ បើសិនជាសហព្រះរាជអាជ្ញាធ្វើការបង្ហាញឯកសារមួយ ឬក៏ពីរនោះ គឺអ្នករាល់គ្នាគឺអាចមានប្រយោជន៍ពីអង្គហេតុនៃការបង្ហាញទាំងអស់នេះ ។ ហើយម្សិលមិញនេះ គឺភាគីរង់ចាំក្នុងការស្តាប់នូវការដេញដោលភស្តុតាង ហើយចំណុចនេះខ្ញុំស្នើសុំ ហើយខ្ញុំចង់ឮការសម្រេចពីខាងអង្គ

សវនាការ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន ។

ខ្ញុំសុំសួរលោក រូ ថាតើលោកឃើញភាពខុសគ្នាយ៉ាងម៉េចរវាងសក្ខីកម្មដែលផ្តល់ជូនដោយអ្នកជំនាញ និងសក្ខីកម្មសាក្សីដែលវាពាក់ព័ន្ធទៅនឹងអង្គហេតុ ពាក់ព័ន្ធជនជាប់ចោទដោយផ្ទាល់? ចំពោះខ្ញុំនោះគឺថាជនជាប់ចោទ គឺជនជាប់ចោទមិនទទួលស្គាល់ទៅលើអង្គហេតុបច្ចេកទេសមួយចំនួនដែលអ្នកជំនាញធ្វើការលើកចោទនោះ ។

ដូច្នេះហើយ សក្ខីកម្មរបស់អ្នកជំនាញ ពេលខ្លះវាអាចមានភាពជាន់គ្នា ប៉ុន្តែនៅពេលខ្លះទៀតវាអាចបំភ្លឺ ហើយវាអាចជួយពន្យល់ឲ្យបានទូលាយទៅលើអង្គហេតុផ្សេងៗចំពោះអង្គសវនាការ ដោយសារមូលហេតុនេះ ទោះបីជាយើងមិនធ្វើការពិភាក្សាសម្រេចទៅលើបញ្ហានេះក៏ដោយ ខ្ញុំឃើញមានភាពខុសគ្នារវាងវិធីសាស្ត្រក្នុងការតាំងសំណួរចំពោះអ្នកជំនាញ នៅពេលដែលយើងផ្តោតទៅលើអង្គហេតុដែលបានព្រមព្រាងគ្នា ដែលលោកកំពុងលើកឡើងនេះ ។ តើលោកចង់លើកឡើងយោបល់ទាក់ទងនឹងបញ្ហានេះដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

អរគុណ លោកស្រីចៅក្រម ។ អរគុណ ដែលផ្តល់ការអនុញ្ញាតដល់ខ្ញុំ ក្នុងការរំឭកអស់លោកលោកស្រី ។ ហើយខ្ញុំសូមគោរពចំពោះការងាររបស់លោកបណ្ឌិត ក្រេក អេតធេសាន់ ទោះបីជាគាត់មិនមែនជាអ្នកជំនាញក៏ដោយ គាត់គឺជាបុគ្គលិករបស់ការិយាល័យសហព្រះរាជអាជ្ញា ។ គាត់នៅទីនេះគឺជាការផ្តល់ទម្ងន់ និងសំឡេងខាងសហព្រះរាជអាជ្ញា ដូច្នេះយើងត្រូវដឹងទៅលើបញ្ហាហ្នឹង ។

[១៤:៥៨:១៦]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

លោកមិនបានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំទេ ដែលជាសំណួរទូទៅ ។ តើលោកទទួលយកសំណើនិងការលើកឡើងរបស់ខ្ញុំដែរឬទេ? គឺវាមានភាពចាំបាច់ក្នុងការពិនិត្យអ្នកសាក្សី អ្នកជំនាញនេះឲ្យបានពិស្តារ ។ ហើយអ្នកជំនាញនេះ គឺគ្រាន់តែលើកឡើងនូវអ្វីដែលជនជាប់ចោទ គាត់បានលើកឡើងរួចហើយនៅក្នុងអង្គហេតុដែលបានព្រមព្រាងគ្នាតែប៉ុណ្ណោះនោះទេ ។ តើលោកទទួលយកដែរឬទេ?

**លោក ហ្វេង់ស្វ័រ រូ៖**

លោកស្រីចៅក្រម ខ្ញុំជឿថា យើងឃើញមានអ្នកជំនាញដែលល្អនឹងមកចូលរួមក្នុងនីតិវិធីនេះ ហើយគាត់នឹងផ្តល់នូវទស្សនទានទូទៅ ហើយរួមទាំងលោក គ្រេក អេតធេសាន់ ផងដែរ ។ ដូច្នេះ ខ្ញុំមានការសង្កេតអំពីភាពចាំបាច់ក្នុងការបញ្ចូលឯកសារ១០ ឬក៏រាប់រយឯកសារក្នុងការគាំទ្រទៅដល់ចម្លើយរបស់អ្នកជំនាញ ទោះបីជាខ្ញុំមិនទាន់មានភាពជឿជាក់ក៏ដោយ ។ ប៉ុន្តែ ប្រសិនមានបញ្ហានោះខ្ញុំនឹងសួរថាតើឯកសារណាដែលគាត់យោង? ប៉ុន្តែនៅពេលនេះ គឺខ្ញុំមិនធ្វើការចាប់ផ្តើមនៅពេលនេះនោះទេ ដោយឲ្យគាត់បង្ហាញឯកសាររាប់រយឯកសារដូច្នោះ ។ ប៉ុន្តែ យើងនឹងមានអ្នកជំនាញដែលល្អៗនឹងមកចូលរួមនៅក្នុងសវនាការរបស់យើង ។ ហើយខ្ញុំមានការចង់ដឹងណាស់ ថាតើអ្នកជំនាញហ្នឹងនឹងនិយាយពីអ្វីខ្លះ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ដូច្នេះ បើសិនជាដូច្នេះមែន វាមិនមែនជាតួនាទីរបស់អង្គសវនាការ ក្នុងការជម្រាបសហព្រះរាជអាជ្ញា ឬក៏ភាគីទាំងឡាយ ថាតើឯកសារណាខ្លះដែលពួកគេគួរតែដាក់ជូនអង្គសវនាការរហូតដល់ភាគីទាំងអស់ពិនិត្យឯកសារនោះជាមុខសិន ។ ដូច្នោះ នៅពេលនោះលោកនឹងមានលទ្ធភាពក្នុងការពិនិត្យទៅលើភាពពាក់ព័ន្ធ និងលក្ខខណ្ឌផ្សេងៗ ដែលជាប់ពាក់ព័ន្ធនឹងឯកសារ ហើយយើងនឹងគោរពតាមទៅការស្នើសុំ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ លោកមេធាវី ។

[១៥:០០:៥៧]

**លោក គង់ ពិសី៖**

ខ្ញុំបាទឈ្មោះ គង់ ពិសី ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ខ្ញុំសូមចូលរួមជាមតិយោបល់បន្តិចនៅក្នុងការដាក់ឯកសារយោងជាភស្តុតាង ។ ចំណុចទីមួយ ខ្ញុំសូមបញ្ជាក់ជូនអំពីច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា បានប្រើស្ថាប័នព្រះរាជអាជ្ញា គឺថាស្ថាប័នអយ្យការ ដើម្បីនាំបណ្តឹងអាជ្ញាយកទៅជូនតុលាការធ្វើការកាត់ក្តី និងជំនុំជម្រះ ។ អ៊ីចឹងស្ថាប័នព្រះរាជអាជ្ញា គាត់មានតួនាទីនៅក្នុងការដាក់បន្ទុកដើម្បីបង្ហាញភស្តុតាងឲ្យច្បាស់លាស់ គឺថាត្រូវបង្ហាញភស្តុតាងឲ្យលើសពីវិមតិសង្ស័យ ។ ដូច្នេះចំពោះការបង្ហាញឲ្យលើសពីវិមតិសង្ស័យនេះ គឺថាមិនដឹងជាកម្រិតណាដើម្បីឲ្យតុលាការជឿថា បាននោះទេ

គឺកម្រិតយ៉ាងហោចណាស់ក៏ ៩៨% ទៅ៩៩% ឬក៏១០០% ទេ នេះហៅថាលើសពីវិមតិសង្ស័យ ។ ដូច្នេះ មិនមានចំណុចណាមួយ ដែលតម្រូវឲ្យព្រះរាជអាជ្ញា ឬក៏កំណត់ព្រំដែនព្រះរាជអាជ្ញាថាត្រូវតែបង្ហាញឯកសារប៉ុណ្ណេះបានហើយ ឯកសារនេះមិនចាំបាច់បង្ហាញបានទេ ។

ដូច្នេះ ខ្ញុំក៏សូមកោតសរសើរ ចំពោះព្រះរាជអាជ្ញាដែលខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំក្នុងការលើកបណ្តឹងអាជ្ញានេះដែរ ហ្នឹងចំណុចទីមួយ ។ ចំណុចទីមួយទៀត ខ្ញុំសូមបង្វែរទៅសេចក្តីរបស់អង្គជំនុំជម្រះ ដែលបានសម្រេចថាឲ្យរបៀបនៃការបង្ហាញភស្តុតាងដែលយោងទៅតាមវិធានផ្ទៃក្នុងវិធាន ៨៧ នេះ គឺថាសូមឲ្យអនុវត្តអាហ្នឹងវិញ ។ បាទ ហើយសូមអរគុណ មានប៉ុណ្ណឹង ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាក១៥នាទី ហើយរហូតដល់ម៉ោង៣:១៥នាទី អញ្ជើញចូលវិញ ។ មន្ត្រីសម្របសម្រួលតុលាការជួយសម្រួលដល់បណ្ឌិត ដើម្បីបានកន្លែងសម្រាកសមរម្យ ។

*[សវនាការសម្រាកពីម៉ោង១៥:០៣នាទី ដល់ម៉ោង ១៥:២២នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តនីតិវិធីសវនាការ ។ មុននឹងជូនវេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើសំណួរពាក់ព័ន្ធទៅនឹងអ្នកជំនាញបណ្ឌិត អេតឆេសាន់ នេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះសាលាដំបូង នឹងធ្វើសវនាការស្តាប់សក្ខីកម្មរបស់អ្នកជំនាញ ណាយ៉ាន់ចាន់ដា នៅដើមសប្តាហ៍ក្រោយគឺនៅថ្ងៃច័ន្ទ ទី២៥ និងថ្ងៃអង្គារ ទី២៦ ខែឧសភា ឆ្នាំ២០០៩ ។ ដោយមូលហេតុគាត់នឹងមកធ្វើសក្ខីកម្មទាក់ទងនឹងអង្គហេតុជម្លោះប្រដាប់អាវុធ ។ បញ្ហាដោយមូលហេតុគាត់មានកិច្ចការជាច្រើនត្រូវធ្វើ ហើយលទ្ធភាពរបស់គាត់អាចមកផ្តល់សក្ខីកម្មបានតែនៅក្នុងអំឡុងថ្ងៃទី២៥ និងថ្ងៃទី២៦ប៉ុណ្ណោះ ។ អ៊ីចឹងសូមភាគីជ្រាបអំពីកិច្ចដំណើរការសវនាការ ដែលយើងគ្រោងធ្វើនៅដើមសប្តាហ៍ក្រោយនេះ ។

ជាកិច្ចបន្ត អង្គជំនុំជម្រះសូមប្រគល់វេទិកានេះ ដើម្បីជូនទៅដល់តំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការសួរសំណួរពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលបានធ្វើការពិភាក្សាដេញដោលទៅនឹង

បណ្ឌិត ក្រេក អេតឆេសាន់ ដែលជាអ្នកជំនាញ ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**សួរដោយ លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោកបណ្ឌិត អេតឆេសាន់ លោកបានសរសេរនៅក្នុងរបាយការណ៍របស់គាត់កាលពីខែសីហា ឆ្នាំ២០០៧ តើលោកអាចប្រាប់តុលាការបានទេ នៅពេលណាដែលលោកបានចាប់ផ្តើមធ្វើការនៅជាមួយការិយាល័យសហព្រះរាជអាជ្ញា?

**ឆ៖** បាទ, ខ្ញុំអាចនិយាយបានលោកសហព្រះរាជអាជ្ញា ។ ខ្ញុំបានធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញានៃ អ.វ.ត.ក នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៦ ។

**ស៖** សម្រាប់ការរៀបចំការសរសេររបាយការណ៍ជាលាយលក្ខណ៍អក្សររបស់លោក លោកបានជ្រើសរើសឯកសារចំនួន១៤៨ ឯកសារមែនទេ? ហើយតើលោកអាចធ្វើការវាយតម្លៃបានទេនៅក្នុងចំណោមឯកសារទាំងអស់នោះ តើឯកសារប៉ុន្មានដែលលោកបានអាន ហើយបានពិចារណានៅក្នុងអំឡុងពេលដែលលោកបានធ្វើការរយៈពេលដប់ពីរខែ មុននឹងលោកចាប់ផ្តើមសរសេររបាយការណ៍នោះ?

ខ្ញុំមិនចង់បានលម្អិតដល់តួអក្សរនីមួយៗនោះទេ? គ្រាន់តែជាចំណុច ឬទៅលើឯកសារដែលលោកបានអាន និងពិចារណានោះ ។

[១៥:២៦:៤២]

**ឆ៖** ខ្ញុំជឿថា យើងបានពិចារណាទៅលើឯកសារចំនួនប្រាំម៉ឺនឯកសារ ។ ហើយក្នុងចំណោមឯកសារទាំងប្រាំម៉ឺននោះ យើងបានជ្រើសរើសចំនួនពីរទៅបីពាន់ឯកសារ សម្រាប់ការពិនិត្យហ្មត់ចត់ ។ ហើយក្នុងចំណោមឯកសារនោះ ខ្ញុំសុំធ្វើការកែសម្រួលលោកបន្តិច គឺថាយើងបានជ្រើសរើសឯកសារចំនួន១៦១ សម្រាប់ការសរសេររបាយការណ៍នេះ ។

**ស៖** ក្នុងន័យទូទៅ តើលោកអាចប្រាប់អង្គសវនាការបានទេ ហេតុអ្វីបានជាលោកជ្រើសរើសឯកសារចំនួន១៦១ឯកសារនោះ ពីចំនួនឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ដែលលោកបានមានប្រសាសន៍អម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំបានជ្រើសរើសឯកសារមួយប្រភេទជាក់លាក់នេះ ពីព្រោះឯកសារអស់ទាំងនេះលាតសន្ធឹងគ្របដណ្តប់ទៅលើបញ្ហាជាច្រើនដែលជាប្រធានបទនៃការសរសេររបាយការណ៍ ។ ហើយនៅក្នុងការពិចារណារបស់យើង គឺខ្ញុំយល់ថា ឯកសារនេះគឺជាឯកសារសមរម្យបំផុត មានន័យថាជាឯកសារ

ដែលបំភ្លឺឲ្យបានច្រើនបំផុតទៅលើចំណុចផ្សេងៗ ដែលនឹងត្រូវយកមកពិចារណា និងវាយតម្លៃនៅក្នុងតុលាការនេះ ។

**ស៖** នៅក្នុងតារាងនៃឯកសារចំនួន១៤៨ ឯកសារ ដែលយើងបានផ្តល់ឲ្យអង្គសវនាការនោះ តើជាប្រភេទឯកសារផ្សេងឬ? ឯកសារនៃភស្តុតាងផ្សេងឬ? មានន័យថាជាការវិភាគ ជារបាយការណ៍វិភាគទៅលើប្រវត្តិរូប ជាសៀវភៅ ។ល។ ប្រសិនបើយើងមើលប្រភេទមួយនៃប្រភេទឯកសារទាំងនោះ ឧទាហរណ៍ថា ខាងផ្នែកទូរលេខ តើលោកអាចប្រាប់អង្គសវនាការបានទេ ហេតុអ្វីបានជាលោកជ្រើសរើសតែចំនួនដប់ប្រាំមួយ ហើយម៉េចក៏មិនព្រមជ្រើសរើសឯកសារ ឧទាហរណ៍ សារទូរលេខតែមួយតែប៉ុណ្ណោះ ។ ខ្ញុំចង់បានតែន័យទូទៅនៃការពន្យល់ទេ ។

**ឆ៖** ខ្ញុំអាចពន្យល់បាន ។ ខ្ញុំបានជ្រើសរើសយកសារទូរលេខចំនួនដប់ប្រាំមួយ ពីព្រោះសារទូរលេខទាំងនេះ បង្ហាញពីប្រភេទផ្សេងៗនៃការធ្វើការទំនាក់ទំនងរវាងអង្គការផ្សេងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយជាមួយនឹងមជ្ឈិមបក្សនៃបក្សកម្ពុជានៃបក្សកុម្មុយនីស្តកម្ពុជា ។ ឧទាហរណ៍សារទូរ-លេខមួយចំនួនបង្ហាញអំពីការទំនាក់ទំនងរវាង លេខាភូមិភាគបូព៌ា ហើយនិងមជ្ឈិមបក្ស ឬលេខានៃភូមិភាគបស្ចិមជាមួយនឹងមជ្ឈិមបក្ស ឬមួយក៏ជាមុខភាគរវាង លេខានៅភូមិភាគពាយ័ព្យ ជាមួយនឹងមជ្ឈិមបក្ស ។ ហើយសារទូរលេខមួយចំនួនទៀតបង្ហាញអំពីការទំនាក់ទនងរវាង លេខានៃលេខាកងពលផ្សេងៗ របស់យោធាបក្សកុម្មុយនីស្តកម្ពុជា ជាមួយនឹងមជ្ឈិមបក្ស ...។ល។

ដូច្នេះ ការជ្រើសរើសប្រភេទ ទូរលេខនេះគឺដើម្បីបង្ហាញនូវប្រភេទផ្សេងៗ នៃការធ្វើការទំនាក់ទំនងរវាងអង្គការផ្សេងៗនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏ជាការបង្ហាញផងដែរនូវការអនុវត្តនៃគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅតំបន់ផ្សេងៗនៃការទទួលខុសត្រូវ ទៅតាមមុខងារនីមួយៗរបស់ខ្លួននោះ ។

[១៥:៣០:៥៦]

**ស៖** ដោយបានធ្វើការជិតពីរឆ្នាំ បន្ទាប់ពីលោកបានសរសេររបាយការណ៍នោះរួចមក តើលោកពិចារណាថា ឯកសារដែលយើងបានជ្រើសរើសនិយាយអំពីសារទូរលេខនោះ ថាតើទូរលេខទាំងដប់ប្រាំមួយហ្នឹង គឺជាចំនួនជាក់លាក់ត្រឹមត្រូវ ដើម្បីបង្ហាញពីអ្វី ដែលលោកទើបបានរៀបរាប់អម្បាញ់មិញនេះឬ?

**ឆ៖** ទេ មិនមែនដូច្នេះទេ ។ ខ្ញុំមិនគិតថាដូច្នេះទេ ។

**ស៖** ខ្ញុំអាចសួរលោកដូច្នេះដែរនូវសំណួរដូចគ្នា ទាក់ទងទៅនឹងឯកសារនីមួយៗបានធ្វើការបែងចែកតាមប្រភេទ ។ ប៉ុន្តែ លោកអាចនឹងសប្បាយចិត្ត ដោយសារខ្ញុំមិនសួរលម្អិតទៅលើឯកសារនីមួយៗតាមប្រភេទនោះទេ ប៉ុន្តែ ខ្ញុំចង់សួរលោកក្នុងន័យទូទៅថាលោកយល់ថា នឹងមានភាពផ្សេងគ្នាទេសម្រាប់ប្រភេទនីមួយៗនៃភស្តុតាង ដែលលោកបានដាក់ក្នុងបញ្ជីនៅក្នុងឯកសារទាំង១៦១ នោះ?

**ឆ៖** ខ្ញុំអាចនិយាយថា ដោយខ្ញុំបានទទួលអត្ថប្រយោជន៍ក្នុងការធ្វើការងាររយៈពេលពីរឆ្នាំទៀត បន្ទាប់ពីបានធ្វើការស្រាវជ្រាវ បន្ទាប់ពីខ្ញុំបានធ្វើសេចក្តីព្រាងទៅលើរបាយការណ៍នោះ គឺខ្ញុំរកបានឃើញនូវឧទាហរណ៍មួយចំនួនទៀត ដែលខ្ញុំយល់ឃើញថាជាឧទាហរណ៍ដ៏ប្រសើរ ជាងឧទារណ៍ដែលខ្ញុំបានដាក់ចូលទៅក្នុងរបាយការណ៍ ។ ក៏ប៉ុន្តែ ការជំនួសឧទាហរណ៍នោះនឹងឧទាហរណ៍ផ្សេងដែលខ្ញុំទទួលបាននៅពេលក្រោយនោះ គឺខ្ញុំមិនអាចធ្វើដូច្នេះបានទេ ពីព្រោះខ្ញុំមិនបានបញ្ចូលព័ត៌មានអ្វីបន្ថែមទៅលើរបាយការណ៍ដែលខ្ញុំបានធ្វើហើយនោះទេ ។

**ស៖** តើខ្ញុំអាចសួរលោកបានទេក្នុងន័យទូទៅ តើក្នុងនាមលោកជាអ្នកជំនាញ លោកធ្វើយ៉ាងម៉េចទៅនៅក្នុងការវិភាគការងាររបស់លោកនោះ? ឧទាហរណ៍ រចនាសម្ព័ន្ធនៃការទំនាក់ទំនង នៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំនឹងបញ្ជាក់អំពីចំណុចជាក់លាក់នេះ ។ ថាតើលោកប្រើឯកសារតែមួយ ឬក៏ឯកសារបីបួន ឬក៏ឯកសារជាច្រើន? ឬក៏តើលោកធ្វើតាមវិធីសាស្ត្រណា?

[១៥:៣៣:៤២]

**ឆ៖** គឺប្រហែលជាមិនអាចនឹងធ្វើការវិភាគ ការទំនាក់ទំនងអាស្រ័យទៅលើឯកសារតែមួយ ឬក៏ឯកសារពីរបី ឬក៏បួននោះទេ ។ ជាឧទាហរណ៍ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានវិធីផ្សេងៗនៃការទំនាក់ទំនងដែលរបបនោះបានប្រើ គឺតាមរយៈសារទូរលេខ តាមរយៈទូរស័ព្ទនៅតាមតំបន់ ទូរស័ព្ទនៅលើតុ តាមរយៈលិខិត ដោយនីរសារជាអ្នកនាំយកទៅឲ្យ តាមរយៈឯកសារ ដោយអ្នកនីរសារជាអ្នកនាំយកទៅឲ្យ ការធ្វើការប្រជុំទល់មុខគ្នា ការប្រជុំជាក្រុម និងការធ្វើអង្គមិទ្ទីង និងការផ្សព្វផ្សាយតាមប្រព័ន្ធវិទ្យុជាតិ និងការបោះពុម្ពផ្សាយរបស់បក្ស ។

ជាសង្ខេបមក គឺថាមានភាពផ្សេងៗគ្នាជាច្រើន នៃការធ្វើទំនាក់ទំនង ហើយដើម្បីឲ្យយល់ដឹងអំពីភាពពេញលេញនៃប្រព័ន្ធបណ្តាញទំនាក់ទំនង គឺត្រូវការធនធានប្រភពផ្សេងៗគ្នា ដើម្បីយកមកពិចារណានិងវិភាគ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

លោកប្រធាន, មុនយើងបានសម្រាកបន្តិចនោះ គឺខាងសហមេធាវីការពារក្តី បានធ្វើការរិះគន់សាក្សីនេះថា គាត់ហ្នឹង គឺជាអ្នកធ្វើការឲ្យខាងការិយាល័យសហព្រះរាជអាជ្ញា ហើយចាត់ទុកថា គាត់ហ្នឹងជាបុគ្គលិកមួយរបស់ខាងការិយាល័យសហព្រះរាជអាជ្ញា ។

ទាក់ទងទៅនឹងសេចក្តីសម្រេចចិត្តរបស់លោកទាក់ទងទៅនឹងវិធាន៨៧ សហព្រះរាជអាជ្ញាចង់ធ្វើការដាក់ជូនដល់អង្គសវនាការថា ទាក់ទងទៅនឹងភស្តុតាងដែលអង្គសវនាការបានឮពីលោកបណ្ឌិតអេតធេសាន់ គឺជាការច្បាស់ណាស់ដើម្បីយល់ថា ភស្តុតាងរបស់គាត់គឺអាស្រ័យទៅលើការវិភាគលម្អិតនៃឯកសារជាច្រើន ហើយជាពិសេសនោះគឺជាការវិភាគជាក់លាក់អំពីប្រភេទតូចៗនៃឯកសារដែលគាត់បានជ្រើសរើសចំនួន១៦១ របាយការណ៍ជាលាយលក្ខណ៍អក្សរនេះ ត្រូវបានសរសេរឡើងមិនមែនជាការយល់ដឹងផ្ទាល់ខ្លួនរបស់គាត់នោះទេ ប៉ុន្តែគឺជាការវាយតម្លៃនៃឯកសារអស់ទាំងនោះ ។

[១៥:៣៦:៤៣]

នៅក្នុងការដាក់ជូនរបស់ខាងការិយាល័យសហព្រះរាជអាជ្ញា ដើម្បីធ្វើការវាយតម្លៃអំពីភាពត្រឹមត្រូវ និងភាពដែលអាចជឿជាក់បាននៃរបាយការណ៍របស់លោក អេតធេសាន់ ជាពិសេសទាក់ទងទៅនឹងសំណើការលើកឡើងរបស់មេធាវីការពារក្តី ដែលថាលោក អេតធេសាន់ គឺគ្រាន់តែជាអ្នកនាំពាក្យរបស់ខាងការិយល័យសហព្រះរាជអាជ្ញានោះ គឺអង្គសវនាការត្រូវធ្វើការវាយតម្លៃទៅលើភាពដែលអាចជឿបាននៃរបាយការណ៍របស់អ្នកជំនាញនេះ ។ ហើយថាតើអង្គសវនាការធ្វើដូច្នេះតាមវិធីណានោះ គឺយើងត្រូវពិនិត្យមើលទៅលើភាពដែលជឿបានទៅលើអត្ថបទនៃរបាយការណ៍នៃឯកសាររបស់សាក្សីនេះដែលជាឯកសារ ដែលសាក្សីនេះយកមកធ្វើជាមូលដ្ឋានសម្រាប់សរសេររបាយការណ៍របស់គាត់ ។

ដូច្នេះ ហើយខ្ញុំសូមស្នើធ្វើសេចក្តីសង្ខេបទៅលើឯកសារនានា ដែលលោក អេតធេសាន់ បានផ្អែកលើនោះ ។ ឯកសារទីមួយ គឺជាឯកសារសំណុំរឿង ជាដីកាបញ្ជូនរឿងឲ្យស៊ើបសួរ គឺ ឧបសម្ព័ន្ធ “គ” ឯកសារ D2.15 លេខ 00087610 រហូតដល់លេខ 00087627 ។

ដើម្បីកាត់បន្ថយនូវដំណើរការនូវនីតិវិធីនេះ ខ្ញុំសូមធ្វើការប្រាប់នូវលេខ ERN ទីមួយនេះ ។ នេះគឺជារបាយការណ៍វិភាគពីប្រភពអន្តរជាតិ ហើយមានចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ៧៨ ហើយជារបាយ-ការណ៍របស់ប្រទេសអាមេរិក សហរដ្ឋអាមេរិក ។ ឯកសារនេះមានចំណងជើងថា “ការដាក់ជូនពីរដ្ឋាភិបាលរបស់សហរដ្ឋអាមេរិកទៅអង្គការសហប្រជាជាតិ” ហើយឯកសារនេះ មានសេចក្តីថ្លែង

ការណ៍របស់ ឌុច ខៀវតារា នៅទំព័រទី៩ ដល់ទំព័រទី១១ និងរបស់ ម៉ុន ស៊ូ នៅទំព័រទី ១៦ ដល់ទី ១៨ និងរបស់ សួ ចេង នៅទំព័រ១៤ ដល់ ១៥ និងរបស់ សោម ប៊ិនណារង្ស៊ នៅទំព័រ៨ ដល់ ៩ និងរបស់ យឹម សុខវ័ន្តជាតិ នៅទំព័រ១១ ដល់១៣ ។ ឯកសារនេះរៀបរាប់អំពីអំពើហឹង្សាទៅលើសិទ្ធិមនុស្ស ដែលមានទ្រង់ទ្រាយធំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមបញ្ចូលទាំង៖

១) គឺនៅទំព័រទី៩ ដល់១១, ១៦ ដល់ ១៩, ១៤ ដល់ ១៥ និយាយអំពីគោលនយោបាយទូទៅក្នុងការឃុំឃាំងមនុស្សទៅតាមសហករណ៍នានា ។

[១៥:៤០:២៦]

២) នៅទំព័រទី១៦ ដល់ ១៨ ទាក់ទងទៅនឹងសហករណ៍ទាំងនេះ ។

៣) នៅទំព័រទី ១៦ ដល់ ១៨ គឺការធ្វើការចាប់បង្ខំ ហើយប្រជាជនត្រូវគេបង្ខំឲ្យធ្វើការច្រើនម៉ោង ។

៤) នៅទំព័រ ៩ ដល់ ១៨ លក្ខណៈរស់នៅអមនុស្សធម៌ ប្រជាជនបានទទួលម្ហូបអាហារមិនគ្រប់គ្រាន់ ការថែទាំផ្នែកសុខភាពមិនបានគ្រប់គ្រាន់ ហើយប្រជាជនត្រូវធ្វើការទោះបីនៅពេលឈឺក៏ដោយ ។

៥) ទំព័រ ៨ ដល់ ១១ និងទំព័រ ១៦ ដល់ ១៨ អំពីការសម្លាប់ក្រៅច្បាប់ អំពីការធ្វើទារុណកម្មប្រជាជនត្រូវបានធ្វើទារុណកម្ម ឬក៏សម្លាប់សម្រាប់អំពើខុសខាតតិចតួចតែប៉ុណ្ណោះ ។

៦) ទំព័រ ៨ ដល់ ១១, ១៣ ដល់១៤ និង ១៦ ដល់ ១៨ មិនមានប្រព័ន្ធច្បាប់ ដែលដំណើរការនោះទេ ។

៧) ទំព័រ ៧ ដល់ ១១ អំពីការសម្លាប់ក្រៅច្បាប់ដល់វេជ្ជបណ្ឌិត ដល់មេធាវី គ្រូបង្រៀន និស្សិត មេដឹកនាំសាសនា អ្នកជំនួញ និងបញ្ញវន្តនានា ។

៨) ទំព័រ ៨ ដល់ ១១ និង ១៣ ដល់ ១៥ ការសម្លាប់ក្រៅច្បាប់ នៃមន្ត្រីសាធារណរដ្ឋខ្មែរឋានៈតូចតាច ហើយនិងយោធាដែលគ្មានឋានន្តរសក្តិ ហើយនិងគ្រួសាររបស់ពួកគេនៅតាមភូមិ និងនៅតាមសហករណ៍ ។

៩) ទំព័រ១១ ដល់ ១៣ គឺការសម្លាប់ប្រជាជននៅតាមភូមិ និងតាមសហករណ៍ ។

១០) ទំព័រ ៨ ដល់ ៩ និយាយអំពីគោលបំណងក្នុងការប្រឆាំងទៅលើជនជាតិវៀតណាម ។

អ៊ឺចឹង ខ្ញុំបានឮការបកប្រែជាភាសាខ្មែរ ក៏ប៉ុន្តែប្រហែលជាមិនមានការបកប្រែជាភាសាអង់គ្លេស។

អ៊ឺចឹង ខ្ញុំនឹងនិយាយឲ្យបានយឺតជាងនេះបន្តិច ។ សូមអរគុណ ។

ត្រឡប់ទៅចំណុច១០ នៃឯកសារនេះដែលខ្ញុំបានសង្ខេប ទំព័រ៨ទៅដល់៩ គឺអំពើរើសអើងចំពោះជនជាតិវៀតណាម ។

១១) ទំព័រ ៨, ៩, ៩ ដល់ ១៣ និង ១៤ ទៅ ១៥ គឺអំពើរើសអើងចំពោះប្រជាជនថ្មី ។

យើងត្រឡប់ចូលឯកសារទីពីរ នៅក្នុងតារាងរបស់លោក ក្រេក អេតធេសាន់ គឺឧបសម្ព័ន្ធ “គ” នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារ D2.15/66 ហើយឯកសារលេខ 2.3 ឯកសារ ERN ជាភាសាខ្មែរគឺ 00087537 ដល់លេខ 00087571 ។ នេះគឺជាឯកសារទី២ ក្នុងចំណោមឯកសារវិភាគចំនួនពីរ ពីឯកសារបរទេសចុះថ្ងៃទី១៨ ខែប្រាំបី ឆ្នាំ១៩៧៨ គឺអ្នកសរសេរ គឺរដ្ឋាភិបាលន័រវេ ។

[១៥:៤៤:៣៣]

សេចក្តីសង្ខេបឯកសារដូចមានដូចតទៅ ៖

ចំណងជើងគឺ “ការដាក់ជូនរបស់រដ្ឋាភិបាលន័រវេ ជូនគណៈកម្មាការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ” ឯកសារនេះមានភស្តុតាងនៃការរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយរួមមាន៖

១) នៅក្នុងទំព័រ១៩ ការកម្ទេច និងការដកហូតទ្រព្យសម្បត្តិ ដោយកម្ពុជាប្រជាធិបតេយ្យ ។

២) នៅទំព័រ១២ បុគ្គលត្រូវបានបង្ខំឲ្យចាកចេញពីភ្នំពេញដោយគ្មានរបស់របរទៅជាមួយ ។

៣) ទំព័រ១២ ដល់១៣ និង ២១ សាកសព យើងឃើញមានសាកសពនៅក្នុងពេល ជម្លៀសដោយបង្ខំ ។

៤) ទំព័រ៤ ដល់៥ និង ទំព័រ១៦ មានការជម្លៀសប្រជាជនចេញពីទីក្រុង ។

៥) ទំព័រទី៨ និង ១៥ ដល់ ១៦ ការបង្ខំឲ្យចាកចេញជំហានទីពីរ ។

៦) ទំព័រទី ៣ គោលនយោបាយផ្លូវការក្នុងការកំណត់ប្រជាជនចូលទៅក្នុងសហករណ៍ ។

៧) ទំព័រ៣ ទំព័រ៨ ដល់ ១០ ឧបសម្ព័ន្ធ ៤ ការតាមដានគឺជាលក្ខណៈសាមញ្ញក្នុងសហករណ៍ ។

៨) ទំព័រ ៩ និង ទំព័រ១៨ អាហារ គឺមិនបានផ្តល់គ្រប់គ្រាន់ ។

៩) ទំព័រ៣ ទំព័រ៩ ទំព័រ១៩ និងឧបសម្ព័ន្ធលេខ៤ មិនមានការព្យាបាលខាងផ្នែកសុខាភិបាលគ្រប់គ្រាន់ ហើយប្រជាជនត្រូវតែធ្វើការងារទោះបីជាឈឺក៏ដោយ ។

១០) ទំព័រ១៨ ដល់ទំព័រទី ១៩ ប្រជាជនស្លាប់ដោយសារការអត់ឃ្លាន និងការហត់នឿយ ។

១១) ទំព័រទី២និងឧបសម្ព័ន្ធទី៤ ប្រជាជនត្រូវបានដាក់ទណ្ឌកម្ម ឬក៏សម្លាប់ដោយកំហុសតូចតាច

១២) ទំព័រ១៣ មិនមានប្រព័ន្ធច្បាប់ដំណើរការ ។

១៣) ទំព័រ១៧ មនោគមវិជ្ជា និងភាពស្មោះត្រង់ទៅដល់បក្ស គឺមានសារសំខាន់ជាងបច្ចេកទេស និងជំនាញ ។

១៤) នៅទំព័រទី ២១ ការសម្លាប់ក្នុងពេលជម្លៀសដោយបង្ខំចេញពីភ្នំពេញ ។

១៥) ទំព័រ៥ ដល់ ៧, ១៣ និង ២១ ការសម្លាប់មន្ត្រីសារធារណរដ្ឋខ្មែរ ហើយនិងមន្ត្រីយោធា ក្នុងខែមេសា និងឧសភា ឆ្នាំ១៩៧៥ ។

[១៥:៤៨:0៥]

១៦) ទំព័រ៨ ប្រជាជនជាច្រើនស្លាប់ក្នុងពេលការបង្ខំឲ្យចាកចេញទៅជនបទ ។

១៧) នៅទំព័រទី១ និង ៨ ដល់ ៩ ការសម្លាប់វេជ្ជបណ្ឌិត មេធាវី គ្រូបង្រៀន សិស្សានុសិស្ស អ្នកដឹកនាំសាសនា អ្នកជំនួញ និងបញ្ញវន្តផ្សេងៗទៀត ។

១៨) ទំព័រ៤ ដល់ ៥, ១៣ដល់ ១៥ និង ឧបសម្ព័ន្ធ៤ ការសម្លាប់មន្ត្រីតូចតាចរបស់សាធារណរដ្ឋខ្មែរ មន្ត្រីមិនមែនបេសកកម្ម យោធាសាមញ្ញ គ្រួសាររបស់គេ អ្នកភូមិ និងសហករណ៍ ។

១៩) ទំព័រ៤ ទៅដល់ ៥ ការសម្លាប់នៅក្នុងភូមិ សម្លាប់ទៅលើសហករណ៍ និងតាមឃុំ ។

២០) ទំព័រ៦ ដល់ ៧ ការសម្លាប់បុគ្គលដែលជាប់ពាក់ព័ន្ធនឹងអ្នកដែលនៅឧត្តរ ។

២១) ទំព័រ១៩ ការរឹបអូសទ្រព្យសម្បត្តិនៅតាមភូមិ និងតាមសហករណ៍ ។

ចំណុចម្ដេពីរ--

**លោក ហ្វេង់ស្វ័រ រ៉ូ៖**

លោកប្រធានខ្ញុំសូមធ្វើការកាត់នៅក្នុងទីនេះ ខ្ញុំសុំអភ័យទោស ដោយសារបញ្ហានេះ។ នៅពេលនេះ ខ្ញុំឮអំពីការរឹបអូសទ្រព្យសម្បត្តិ និងការប្រមូលនៅក្នុងសហគមន៍ នៅក្នុងសហករណ៍ ហើយខ្ញុំអត់ឃើញមាននៅក្នុងដីកាដំណោះស្រាយ ដែលដាក់ជូនដោយចៅក្រមស៊ើបអង្កេតនោះទេ ។ ដូច្នេះ លោក ឌុច គឺត្រូវបានគេចោទប្រកាន់នៅទីនេះ បន្ទាប់ពីការស៊ើបអង្កេតក្រោយមួយឆ្នាំមកតាមរយៈដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះ ដោយផ្អែកលើអង្គហេតុប្រព្រឹត្តនៅស-២១ ។ ហើយខ្ញុំនៅពេលនេះឮអំពីអង្គហេតុអំពីសហករណ៍ ហើយខ្ញុំឮអំពីមនុស្សទាំងឡាយដែលត្រូវបានដេញចេញភ្នំពេញ និងជម្លៀសពីភ្នំពេញ ។ ហើយខ្ញុំឮអង្គហេតុទាក់ទងអំពីប្រព័ន្ធច្បាប់ដែលមិនមានដំណើរការក្នុងប្រទេស ។ អង្គហេតុទាំងអស់នេះ គឺវាស្ថិតនៅក្រៅអង្គហេតុនៅក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ ។

[១៥:៥០:៥៣]

ដូច្នេះ ខ្ញុំចង់ឲ្យសហព្រះរាជអាជ្ញាចូលទៅដល់អង្គហេតុ ដែលយើងពិភាក្សានៅទីនេះ ។ ហើយ ឌុច គឺគាត់ជាប់ទាក់ទងទៅនឹងអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ដូច្នេះ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញាផ្តោតទៅលើអង្គហេតុ ដែល ឌុច ស្ថិតនៅក្នុងក្រោមការចោទប្រកាន់តាមរយៈដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ ។ យើងមិនអាចចោទប្រកាន់ ឌុច ទៅលើអង្គហេតុគ្រប់ទាំងអស់នៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ដូចជាតាមសហករណ៍ ការជម្លៀស ការរឹបអូសទ្រព្យសម្បត្តិ... ។ល។ នោះជាដើមនោះទេ ដែលសហព្រះរាជអាជ្ញាបានលើឡើងនៅពេលនេះ ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាចង់មានយោបល់អី ។ តបនឹងការកត់សម្គាល់របស់មេធាវី ឬយ៉ាងម៉េច?

សូមព្រះរាជអាជ្ញាមានការចាប់អារម្មណ៍ ដោយសារការកត់សម្គាល់របស់មេធាវីការពារជនជាប់ចោទជាការសមរម្យមួយចំនួន ។ ពិតហើយមួយចំនួនទៀត ដូចជាអទិភាព១នៃតុលាការក៏មានការពាក់ព័ន្ធនៅក្នុងបង្ហាញនៅក្នុងអង្គហេតុនៃការចោទប្រកាន់មួយដែរ ។ ដោយឡែក បញ្ហាផ្សេងទៀត គឺមិនពាក់ព័ន្ធនឹងការចោទប្រកាន់ទេ ។ អ៊ីចឹង គ្រាន់តែការសង្ខេបរបស់លោកគួរតែត្រូវបានដកស្រង់នូវអ្វីដែលមានការពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានចោទប្រកាន់ ហើយនិងបានធ្វើ កំពុងតែធ្វើការពិភាក្សាដេញដោល ។ សូមរំឭក ។

សូមអញ្ជើញ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសង្ឃឹមថា ខ្ញុំបានបង្ហាញអំពីហេតុផល ហើយនិងភាពចាំបាច់ទាំងឡាយចំពោះឯកសារដែលលោក អេតឆេសាន់ បានយកមកធ្វើជាសំអាង ហើយអាន គឺយកឯកសារនេះមកអានក្នុងតុលាការ ។ ខ្ញុំអាចបញ្ជាក់ឲ្យច្បាស់ជាងនេះបន្តិច ឯកសារទាំងអស់នេះ គឺជាឯកសារដែលអ្នកជំនាញមួយនេះគិតថាវាមានផលប្រយោជន៍ ហើយគាត់យកមកផ្អែកនៅក្នុងសក្ខីកម្មនិងរបាយការណ៍របស់គាត់ ។ ខាងការពារកំពុងតែតវ៉ា ហើយលើកឡើងថា សាក្សីមួយនេះគឺជាអ្នកនាំពាក្យរបស់សហព្រះរាជអាជ្ញា ។ ដូច្នេះ គឺជាអង្គសវនាការជាអ្នកវាយតម្លៃទៅលើភស្តុតាងដែលលោក

បណ្ឌិត អេតឆេសាន់ បានយកមកធ្វើជាសំអាង ។

[១៥:៥៣:៤៧]

សេចក្តីសង្ខេបរបស់ឯកសារខ្ញុំ គឺគ្រាន់តែចង់ផ្តល់ជាមូលដ្ឋានក្នុងការវាយតម្លៃសម្រាប់អង្គសវនាការ ដោយក្នុងការធ្វើការសន្និដ្ឋានចំពោះលោកបណ្ឌិត ក្រេក អេតឆេសាន់ ។ ហើយខាងមេធាវីការពារក្តីហាក់ដូចជាភ្លេចថា ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើជនជាប់ចោទនោះ សហព្រះរាជអាជ្ញាត្រូវតែបង្ហាញឲ្យហួសពីវិមតិសង្ស័យថា ឧក្រិដ្ឋកម្មបានកើតឡើងក្នុងលក្ខណៈប្រព័ន្ធនិងទូលំទូលាយទូទាំងប្រទេស ។ វាមិនដូចគ្នាក្នុងការនិយាយថា ជនជាប់ចោទទទួលខុសត្រូវទូទាំងប្រទេសនោះទេ ។ យើងត្រូវបង្ហាញថា ឧក្រិដ្ឋកម្មដែលយើងលើកឡើងនោះត្រូវបានប្រព្រឹត្តឡើងដោយជនជាប់ចោទនៅស-២១ ។ ហើយឧក្រិដ្ឋកម្មទាំងអស់នោះជាផ្នែកមួយនៃការវាយប្រហារជាទូទៅ និងប្រព័ន្ធលើប្រជាជនស៊ីវិលមួយផ្នែក និងទាំងស្រុង ។ នេះជាមូលហេតុមូលដ្ឋាននៃការបញ្ចូលឯកសារទាំងអស់នេះក្នុងសេចក្តីសង្ខេបរបស់ខ្ញុំ ។

ខ្ញុំគិតថា វាជាពេលមួយដែលដល់ហើយក្នុងការដាក់ជូននូវសេចក្តីសង្កេតរបស់ខ្ញុំ ដើម្បីឆ្លើយតបទៅនឹងការជំទាស់និងការកាត់របស់ខាងមេធាវីការពារក្តី ។ សហព្រះរាជអាជ្ញា គឺយល់ច្បាស់ណាស់ថាមេធាវីការពារក្តីមានបំណងក្នុងការដាក់កម្រិតអង្គសវនាការក្នុងការពិចារណាទៅលើភស្តុតាង តែកម្រិតនោះ គឺកម្រិតឲ្យពិនិត្យលើឯកសារមួយចំនួនតូចតែប៉ុណ្ណោះ ។ ជាការពិតណាស់ គឺវាជាផលប្រយោជន៍សម្រាប់ជនជាប់ចោទ គឺថា នៅពេលដែលយើងមិនពិនិត្យ មិនសូវពិនិត្យមើលទៅលើឯកសារដាក់បន្ទុកនិងឯកសារមូលដ្ឋានមួយចំនួន ។ ប៉ុន្តែ លោកប្រធានជាទីគោរព! មុខនាទីរបស់សាលាក្តីមួយនេះ គឺអង្គជំនុំជម្រះសាលាដំបូងគឺត្រូវការធ្វើវិនិច្ឆ័យនិងបង្ហាញថា សាលាក្តីដែលមានលក្ខណៈអន្តរជាតិ ដែលមានទីតាំងក្នុងប្រទេសកម្ពុជាដោយមានបុគ្គលិកចៅក្រមជាតិនិងអន្តរជាតិ ហើយធ្វើការសម្រេចដោយយុត្តិធម៌ ដោយផ្អែកទៅលើភស្តុតាងដែលមាន ។ ហើយអ្វីដែលសំខាន់ជាងនេះទៀតនោះ សវនាការត្រូវធ្វើជាសាធារណៈ ហើយសាលក្រមត្រូវផ្អែកទៅលើភស្តុតាងដែលបង្ហាញដេញដោលជាសាធារណៈ ។

[១៥:៥៦:៥៦]

យើងឃើញមានរបាយការណ៍ជាច្រើនដែលកើតចេញនៅក្នុងប្រទេស ហើយតុលាការនៅក្នុងប្រទេសនេះ គឺត្រូវធ្វើឲ្យមានតម្លាភាព ហើយធ្វើជាសាធារណៈទៅលើភស្តុតាងទាំងអស់នោះ ។ គឺរបាយការណ៍ដែលកើតចេញនៅក្នុងសាលាក្តីមួយនេះ ដែលពាក់ព័ន្ធទៅនឹងបញ្ហានៃអំពើពុករលួយ ។

ហើយអ្វីដែលយើងចង់បាននោះនៅក្នុងដំណើរការរបស់យើងនៅទីនេះ នៅពេលដែលអ្នកជំនាញគាត់មើលឡើងវិញ ហើយពិនិត្យថា តើសវនាការធ្វើឡើងតាមរបៀបណានោះ? គឺអ្នកជំនាញចង់មើលឃើញថា សាលក្រមនោះផ្អែកទៅលើឯកសារនិងភស្តុតាងទាំងឡាយ ឬក៏សាលក្រមនោះផ្អែកទៅលើឯកសារផ្សេងៗ ។

តើយើងចង់ឲ្យអ្នកជំនាញអស់ទាំងនោះ នៅពេលដែលគាត់មើលបកមកក្រោយវិញ មើលទៅលើនីតិវិធីដែលយើងកំពុងដំណើរការ ហើយនិយាយថា សេចក្តីសម្រេចនោះ គឺអាស្រ័យទៅលើភស្តុតាងជាក់លាក់ អាស្រ័យទៅលើប្រភពឯករាជ្យហើយដែលជាប្រភពបញ្ជាក់អំពីភស្តុតាងទាំងនោះ ។

លោកប្រធានសហព្រះរាជអាជ្ញាចង់ឲ្យមានការកាត់ក្តីដែលលឿននិងឆាប់រហ័ស ហើយដែលត្រឹមត្រូវ និងយុត្តិធម៌ ។ ក៏ប៉ុន្តែ ពួកយើងក៏ធ្វើការពិចារណាផងដែរ ថាសាធារណជនមានសិទ្ធិក្នុងការស្តាប់ឮនូវភស្តុតាងដែលត្រូវបានរកឃើញសម្រាប់ជាការធ្វើសម្រេចសាលក្រមនៅចុងក្រោយ ។ ហើយខ្ញុំសូមធ្វើការនិយាយថា អង្គសវនាការនេះគឺថា មាននាទីដើម្បីធ្វើការណែនាំពន្យល់ និងបង្ហាញអំពីដំណើរការនៃតុលាការនេះ ដូចខាងក្រោម ។ ហើយខ្ញុំក្នុងនាមជាសហព្រះរាជអាជ្ញា សូមឲ្យលោកប្រធានធ្វើការអនុវត្តនូវគោលការណ៍នេះ ។ សម្រាប់ហេតុផលដែលខ្ញុំបានលើកខាងលើនេះ គឺថាខ្ញុំមិនសុំទោសនៅក្នុងការអានសេចក្តីសង្ខេបនៃឯកសារដែលអ្នកជំនាញនេះបានយកមកធ្វើជាមូលដ្ឋាននោះទេ ។ ហើយដោយមានការអនុញ្ញាតពីអង្គសវនាការ ខ្ញុំនឹងបន្តការអានរបស់ខ្ញុំតទៅទៀត ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៩:៥៩]

**លោក គង់ ពិសី៖**

សូមលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលើកម្តងពីរ ។ អញ្ជើញមេធាវីមានបញ្ហាអីទៅ?

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពអង្គជំនុំជម្រះ! ខ្ញុំបាទធ្វើការសង្កេតទៅដែល លោកសហព្រះរាជអាជ្ញាបានលើកឡើងនូវឯកសារនេះ គឺថាខ្ញុំបាទរកទៅពុំឃើញជាភាសាខ្មែរទេ ហើយប្រហែលជាមានតែភាសាអង់គ្លេស ហើយប្រសិនណាជាភាគីមេធាវីការពារមានហ្នឹងអាចចែកមកខាង

ខ្ញុំមកផង ហើយប្រសិនណានៅតែអត់មានដដែលអ៊ីចឹងទៀត គឺថាវាផ្ទុយទៅនឹងច្បាប់ អ.វ.ត.ក ហើយជាពិសេសវាផ្ទុយទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានចូលមកដោយអង្គជំនុំជម្រះនៅថ្ងៃម៉ោង នៅថ្ងៃនេះ បានបញ្ជាក់ថា ឯកសារទាំងអស់ត្រូវតែជាពិសេសគឺត្រូវតែមានភាសាខ្មែរ ដើម្បីជាផលប្រយោជន៍នៅក្នុងតុលាការនេះ នុ៎ងទីមួយ ។ ទីពីរដើម្បីជាផលប្រយោជន៍ដល់ជនជាប់ចោទផង ក៏ប៉ុន្តែមិនបានលើកឡើងពីដើមបណ្តឹងរដ្ឋប្បវេណីទេ ។ អ៊ីចឹងទេ ខ្ញុំបាទសូមសំណូមពរថាធ្វើយ៉ាងម៉េចឲ្យមានជាភាសាខ្មែរ ដើម្បីឲ្យបានប្រើប្រាស់នៅក្នុងសាលាក្តីនេះ ។ សូមអរគុណ ។

[១៦:១១:៣៩]

**លោក អាឡាំង វ៉ែនណឺ៖**

លោកចៅក្រម នឹងផ្តល់សេចក្តីសម្រេចទៅលើចំណុចដែលសំខាន់ ។ មុនពេលដែលលោកចៅក្រមចេញសេចក្តីសម្រេចនោះ គឺខ្ញុំសូមស្នើសុំ ហើយនិយាយដោយសង្ខេប ហើយសហសេវិករបស់ខ្ញុំក៏ចង់លើកឡើងដែរ ហើយលោក រ៉ូ ក៏នឹងធ្វើការឆ្លើយតប ។ ហើយប្រសិនបើលោក លោកស្រីចៅក្រមនឹងធ្វើការសម្រេចទៅលើបញ្ហានេះ យើងខ្ញុំសូមដាក់ជូននូវសេចក្តីសន្និដ្ឋានរបស់ខ្ញុំផងដែរ ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញា តើឯកសារសង្ខេបអម្បាញ់មិញនេះ ដែលបានលើកឡើងដោយមេធាវីជាតិក្រុមពីរ គាត់បានលើកឡើងអំពីភាសាដែលប្រើប្រាស់ ភាសាដើមនុ៎ង គឺជាភាសាខ្មែរដែលត្រូវប្រើប្រាស់នុ៎ង តើមានឯកសារសង្ខេបដែលអានអម្បាញ់មិញនេះជាភាសាខ្មែរដែរ ឬទេ?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

ជាការពិត គឺមាន ។ ខ្ញុំសូមឲ្យលេខយោងទៅលើភស្តុតាងនេះ គឺលេខ 00224335 ដល់លេខ 00224356 គឺឯកសារលេខ១ នៅក្នុងលេខ អ៊ីនឌីក ហើយឯកសារលេខ២ ដែលខ្ញុំហៀបនឹងបញ្ចប់នូវសេចក្តីសង្ខេបរបស់ខ្ញុំហើយមុននោះ គឺជាភាសាខ្មែរមានលេខERN00228717 ដល់លេខ00228765។ លោកប្រធាន ខ្ញុំគួរតែសូមបន្ថែមថា លេខយោង ERN ទាំងអស់គឺមាននៅក្នុងលេខ អ៊ីនឌីក នៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់លោក ក្រេក អេតឆេសាន់ គឺលេខ E55.1 ភាសាដើម គឺភាសាអង់គ្លេស ហើយលេខERN បន្ថែម គឺរៀបរាប់អំពីលេខយោងខ្មែរ ឬបារាំង ឬក៏ទាំងពីរ ហើយប្រសិនភាសាដើម គឺភាសាខ្មែរ លេខយោង ERN បន្ថែមនោះ គឺអាចជាភាសា អង់គ្លេស ឬក៏បារាំង ឬក៏ទាំងពីរ ។

[១៦:១៥:០៦]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន តើសហព្រះរាជអាជ្ញាអាចធ្វើការចង្អុលបង្ហាញបានដែរឬទេ ថាសេចក្តីសង្ខេបដែលសហព្រះរាជអាជ្ញាកំពុងតែអាននោះ វាមានជាភាសាខ្មែរ និងបារាំងដែរឬទេ?

ជាការពិតជាក់ស្តែង យើងនឹងមិនធ្វើការពិចារណាទៅលើឯកសារពេញលេញនៃឯកសារសង្ខេបរបស់សហព្រះរាជអាជ្ញានោះទេ ហើយមើលលើឯកសារ ៩,១០,១៣,១៤ ...។ល។ នោះទេ ។

ដូច្នេះ សេចក្តីសង្ខេបដែលទាក់ទងនឹងឯកសារ E55.1 នោះមានជាភាសាខ្មែរដែរឬទេ? សម្រាប់ឲ្យមេធាវី ហើយនិងជាភាសាបារាំងសម្រាប់ខ្ញុំដែរឬទេ? ខ្ញុំនិយាយអំពីសេចក្តីសង្ខេបឯកសាររបស់សហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗតំណាងសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ លោកប្រធាន ។ ឯកសារសង្ខេបនៅក្នុង អ៊ីនឌីក E55.1 នោះមានតែជាភាសាអង់គ្លេសតែមួយគត់តែប៉ុណ្ណោះ ។ ប៉ុន្តែ ឯកសារទាំងស្រុងត្រូវបានបកប្រែទៅជាភាសាខ្មែរដោយពេញលេញ ហើយបកប្រែជាភាសាបារាំង ក៏បកទាំងអស់ពេញលេញដែរ ។ ខ្ញុំសូមផ្តល់ជូនការបកប្រែសំខាន់ដែលយើងមាន ដែលយើងមាននៅក្នុងនីតិវិធីរបស់យើង ។ សេចក្តីសង្ខេបដែលខ្ញុំអានជាភាសាអង់គ្លេសនេះ នឹងមានប្រហែលជាមាននៅថ្ងៃស្អែក សម្រាប់គ្រប់ភាគីទាំងអស់ដើម្បីធ្វើការពិនិត្យ ។

ខ្ញុំគួរតែបញ្ជាក់ថា សេចក្តីសង្ខេបជាភាសាអង់គ្លេសដែលខ្ញុំអាននេះ នឹងមាននៅក្នុងប្រតិចារឹកនៃនីតិវិធីរបស់យើង ។ ដូច្នេះនៅពេលផ្តល់ឯកសារពេញលេញទាំងស្រុងនូវឯកសារនេះ ដោយរួមជាមួយនឹងប្រតិចារឹកដែលមាន សហព្រះរាជអាជ្ញាគិតថា យើងបានបំពេញទៅតាមលក្ខខណ្ឌដែលតម្រូវឲ្យមានឯកសារបកប្រែតាមដីការបស់លោកចៅក្រម ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:២៤:២២]

**ប្រធានអង្គជំនុំ៖**

អម្បាញ់មិញនៅការងារឃើញថា ការប៉ុនប៉ងរបស់មេធាវី អាឡាំង វ៉ែនណឺ ដែលមានការ

ប៉ុនប៉ងលើកឡើង ឬក៏ដាក់ជូននូវសេចក្តីសន្និដ្ឋានរបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានេះ ។ ដល់ពេលនេះតើលោក អាឡាំង វ៉ែនណឺ នៅតែមានការប៉ុនប៉ងដាក់បញ្ហា ឬសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងបញ្ហានេះដល់អង្គជំនុំជម្រះដែរឬទេ? បើមានការប៉ុនប៉ងសូមអញ្ជើញ តើដាក់យ៉ាងម៉េចទៅ?

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំសូមអរគុណ ហើយខ្ញុំនឹងនិយាយដាក់ជូនដោយសង្ខេប គឺខ្ញុំនិយាយសង្ខេបចំណុចចំនួនពីរ ។ លោកចៅក្រមបានចេញសម្រេចថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ទាក់ទងនឹងការចាត់តាំងភារកិច្ចរបស់អ្នកជំនាញ ។ ចំណុចទីបួនទាក់ទងទៅនឹង ក្រេក អេតឆេសាន់ ។

ដូច្នេះ ចំណុចដំបូង ខ្ញុំចង់លើកឡើងនោះ នៅក្នុងការលើកឡើងសេចក្តីសន្និដ្ឋានរបស់យើងខ្ញុំ វាគឺជាភាគីខាងមេធាវីការពារក្តីដែលលើកឡើងថា លោកបណ្ឌិត ក្រេក អេតឆេសាន់ មិនមែនជាអ្នកជំនាញ ប៉ុន្តែ លោកចៅក្រមបានចេញនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ គឺថាគាត់ជាអ្នកជំនាញ ហើយមកផ្តល់សក្ខីកម្ម ។ ហើយចំពោះវិសាលភាពនៃសក្ខីកម្មរបស់គាត់នៅក្នុងចំណុច៣ ចំណុច៤ គឺលោក ក្រេក អេតឆេសាន់ នឹងមកនិយាយអំពីរចនាសម្ព័ន្ធនយោបាយរបស់ខ្មែរក្រហម គោលនយោបាយ និងមនោគមវិជ្ជាខ្មែរក្រហម ។

មនោគមវិជ្ជា និងគោលនយោបាយដែលយើងដឹងនោះ គឺវាទាក់ទងទៅនឹងការកម្ទេចបុគ្គលក្នុងប្រទេសកម្ពុជា ការធ្វើទារុណកម្មនៅក្នុងប្រទេសកម្ពុជា ។ ប្រសិនបើសហព្រះរាជអាជ្ញាសម្រេចសង្ខេបទៅលើភស្តុតាងដែលលោក ក្រេក អេតឆេសាន់ បានផ្អែកនោះ យើងត្រូវតែធ្វើដូច្នោះ ដូចដែលគាត់ពន្យល់ ។ ដោយសារតែឯកសារនោះគឺជាឯកសារដែលលោក ក្រេក អេតឆេសាន់ ផ្អែកទៅលើ ហើយលោកចៅក្រមបានចេញសេចក្តីសម្រេចនៅល្ងាចនេះហើយ អ៊ូ!នៅល្ងាចនេះ ល្ងាចមុននេះ គឺទាក់ទងទៅនឹងសេចក្តីសម្រេច ។ ហើយប្រសិនបើសហព្រះរាជអាជ្ញាសម្រេចថា គាត់ត្រូវតែធ្វើសេចក្តីសង្ខេបគាត់ត្រូវតែសេចក្តីសង្ខេប ហើយសេចក្តីសង្ខេបរបស់គាត់មិនមែននិយាយអំពីកម្ពុជាទាំងមូលនោះទេ គឺនិយាយអំពីស-២១ និងចំណុចផ្សេងៗ ។

ដូច្នេះហើយយើងសូមជំទាស់ទៅនឹងការជំទាស់របស់មេធាវីការពារក្តី ដោយវាគ្មានមូលដ្ឋានត្រឹមត្រូវ និងជាក់ស្តែង ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**លោកស្រី អេលីហ្សាប៉ែត វ៉ាបេសាន់ដ្រាតាណា៖**

លោកប្រធាន ខ្ញុំចង់ធ្វើសេចក្តីសន្និដ្ឋានទាក់ទៅនឹងអ្វីដែលសហសេវិករបស់ខ្ញុំបាននិយាយ ហើយជាការគាំទ្រដល់អ្វីដែលគាត់បានលើកឡើង ។ នៅក្នុងសេចក្តីសម្រេចរបស់លោក នៅថ្ងៃទី២៣ ខែ៤ ០៩ គឺឯកសារលេខ E51 អង្គសវនាការបានអញ្ជើញលោក ក្រេក អេតឆេសាន់ ដើម្បីធ្វើសក្ខីកម្មទៅលើរចនាសម្ព័ន្ធយោធា នយោបាយ និងអង្គការចាត់តាំងរបស់ខ្មែរក្រហម និងបណ្តាញទំនាក់ទំនងរបស់របបនោះ ព្រមទាំងគោលនយោបាយ និងមនោគមវិជ្ជានៃរបបនោះ ។

បន្ទាប់មកទៀត ដូចដែលលោកប្រធានបាននិយាយពីមុនមក គឺនឹងមានគោលបំណងដើម្បីឲ្យលោក ដេវីដ ឆេនល័រ មកផ្តល់សក្ខីកម្មអំពីការស្រាវជ្រាវរបស់លោកទៅលើមន្ទីរស-២១ ។ ខ្ញុំពិនិត្យមើលឃើញថា វាមិនមានហេតុផលត្រឹមត្រូវសោះ ដែលមេធាវីការពារក្តីងើបឡើងនិយាយថា “អ្នកសាក្សីដែលជាអ្នកជំនាញនេះ គឺកម្រិតទៅលើតែឧក្រិដ្ឋកម្មដែលបានធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទទាក់ទងទៅនឹងស-២១ តែប៉ុណ្ណោះ ជាពិសេសនៅក្នុងអំឡុងពេលសវនាការពីម្សិលមិញ គឺថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩ ។ មេធាវីការពារក្តីបានងើបឡើង ហើយនៅពេលដែលសាក្សីកំពុងតែធ្វើសក្ខីកម្មនោះ ហើយគាត់បាននិយាយថាសាក្សីដែលជាអ្នកជំនាញនេះ បានធ្វើ បាននិយាយហួសពីព្រំដែននៃរបាយការណ៍របស់គាត់ ហើយបានធ្វើការវិភាគ ដែលការវិភាគរបស់គាត់នោះ គឺវាមិនស៊ីគ្នាទៅនឹងរបាយការណ៍របស់គាត់ ពីព្រោះអី គាត់បាននិយាយយោងទៅលើស-២១ ហើយមេធាវីការពារក្តីនៅពេលនោះ គាត់បាននិយាយថា គឺជានយោបាយ គឺជារបាយការណ៍និយាយពីគោលនយោបាយទូទៅដែលបានរៀបចំឡើងនៅឆ្នាំ២០០៧ ហើយមិនអ្វី ឬក៏មិនគួរនិយាយអ្វីទាក់ទងទៅនឹងស-២១ ទេ ពីព្រោះស-២១ ហ្នឹងគឺវាមានឡើងនៅពេលក្រោយ ។

ឥឡូវនេះ ខាងមេធាវីការពារក្តីបានធ្វើសេចក្តីសន្និដ្ឋានទៀតថា គឺសេចក្តីសន្និដ្ឋានដែលផ្ទុយគ្នាទៅនឹងអ្វីដែលគាត់បានលើកឡើងកាលពីមុននោះ មានន័យថា គាត់ធ្វើការកម្រិត ចង់កម្រិតទៅលើលទ្ធភាពរបស់ខាងសហព្រះរាជអាជ្ញាឲ្យត្រឹមតែនៅស-២១ តែប៉ុណ្ណោះ ពីព្រោះនីតិវិធីនៅថ្ងៃនេះ គឺមិនមែននិយាយតែទៅលើប្រតិបត្តិការរបស់ស-២១ នោះទេ ប៉ុន្តែនិយាយអំពីគោលនយោបាយទូទៅរបស់កម្ពុជាប្រជាធិបតេយ្យ ។

ដូចដែលមានចែងនៅក្នុងសេចក្តីសម្រេចនោះ ហើយដើម្បីហេតុផលហ្នឹងហើយ ដែលលោកលោកស្រីចៅក្រមបានអញ្ជើញ លោក អេតឆេសាន់ មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គសវនាការនេះ ។

ដូច្នេះនេះគឺជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ដែលថា មេធាវីការពារក្តីមិនអាចកម្រិតទៅលើភស្តុតាងណាដែលអាចទទួលបាន ឬក៏មិនទទួលបាន ឬក៏ទម្រង់នៃភស្តុតាងដែលទទួលបាន ឬមិនទទួលបាន ដែលគេព្រមឬក៏មិនព្រមព្រៀងនោះទេ ។ ហើយមិនអាចដូចថាដាក់កម្រិតទៅឲ្យខាងសហព្រះរាជអាជ្ញា កម្រិតទៅលើប្រភេទនៃឯកសារដែលជាមូលដ្ឋាននោះ ។

ទាក់ទងទៅនឹងមាត្រា៨៧ ភស្តុតាងទាំងអស់ត្រូវតែដាក់បង្ហាញនៅចំពោះមុខអង្គសវនាការ ហើយនេះគឺជាតុលាការរបស់លោក លោកស្រីចៅក្រម ដែលជាអ្នកកំណត់ទៅលើភាពពាក់ព័ន្ធ ឬក៏ទំងន់នៃភស្តុតាងនោះ ហើយសាក្សីទាំងអស់ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការនេះ គឺមានស្ថានភាពដូចគ្នាអ៊ីចឹង ។

ដូច្នេះ គឺអង្គសវនាការជាអ្នកកំណត់ទៅលើតម្លៃៗនៃសំណុំរឿងនីមួយៗ ដែលមានចំពោះមុខរបស់លោក លោកស្រីចៅក្រមតាមរយៈសាក្សីដែលមកផ្តល់សក្ខីកម្មនោះ ។ សាក្សីដែលជាអ្នកជំនាញរបស់ខាងសហព្រះរាជអាជ្ញាក៏មិនអាចត្រូវបានពិចារណាថា គាត់ហ្នឹងមិនមានតម្លៃឲ្យបានគ្រប់គ្រាន់ជាងដូចជាសាក្សីជំនាញដែលខាងមេធាវីការពារក្តីលើកឡើងនោះទេ ។ ពីព្រោះយើងធ្វើទៅតាមនីតិវិធីដែលយើងមាននេះ ហើយសម្រាប់ដើម្បីទទួលបាននូវការពិតនោះ ការបង្ហាញភស្តុតាងគឺជាចំណុចសំខាន់ណាស់ ហើយខ្ញុំធ្វើការគាំទ្រទៅនឹងវិធីសាស្ត្រដែលសហព្រះរាជអាជ្ញាបានលើកឡើង និងបានធ្វើឡើងនៅពេលនេះ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

មានទៀតទេ ខាងមេធាវី ។ ជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ជៀសវាងវិលៗទៅចប់ហើយទៅទៀត ។ ដូច្នេះ ឥឡូវឲ្យភាគីខាងណេះ ឲ្យចង់សព្វគ្រប់ ខាងណេះឆ្លើយតបដើម្បីបញ្ចប់នូវព័ត៌មានផ្សេងៗដែលទទួលយកបាន ប្រមូលដើម្បីយកទៅពិចារណាសម្រេចតែម្តង ។

អញ្ជើញលោក ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

សូមអរគុណ ជាបន្តខ្ញុំបានសូមគោរពលោកប្រធាន ។ ក្នុងនាមខ្ញុំបានជាមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបួន មិនមានអ្វីវែងឆ្ងាយទេ ខ្ញុំបាទគ្រាន់លើកឡើងក្នុងការគាំទ្រដល់សហមេធាវី

ជាតិ និងអន្តរជាតិ ខាងផ្នែកដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីជនជាប់ចោទ ។

**លោក ហ្រ្វង់ស្វ័រ រ៉ូ៖**

លោកប្រធាន សូមអរគុណ ។ ខ្ញុំមានការអង្កេតមើលចំនួនច្រើនដែលខ្ញុំត្រូវធ្វើ ជាដំបូងបង្អស់ខ្ញុំចង់ធ្វើការបញ្ជាក់ដល់សហសេវិករបស់ខ្ញុំទាំងអស់នៅពេលដែលខ្ញុំនិយាយថា ខ្ញុំនិយាយអំពីអ្នកជំនាញដែលមេធាវីការពារក្តីបានលើកឡើង ។ ឧទាហរណ៍ថា លោក ដេវីដ ឆេនល័រ គឺជាអ្នកជំនាញ ដែលជាការសំណាងណាស់ ប្រសិនបើយើងមានគាត់មកចូលនៅក្នុងដំណើរការនីតិវិធីរបស់យើង ។ ហើយខ្ញុំក៏បានឮផងទៀតដែលអំពីបញ្ហានៃវិធីសាស្ត្រ និងបញ្ហាទាក់ទងទៅនឹងវប្បធម៌ ប្រសិនបើខ្ញុំបាននិយាយដូច្នេះ ។ ខ្ញុំបាននិយាយជាច្រើនដងមកហើយថា យើងមានវត្តមាននៅទីនេះ បន្ទាប់ពីមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រោយពីមានការស៊ើបអង្កេតរយៈពេលមួយឆ្នាំកន្លងមក ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតទាំងពីរ ។ នៅក្នុងការស៊ើបអង្កេតនោះ ដែលមានការចូលរួមជាប្រចាំ និងជាប្រព័ន្ធ គឺមានវត្តមានរបស់សហព្រះរាជអាជ្ញា ហើយខ្ញុំចង់សូមថាធ្វើការ អរគុណពួកគេចំពោះចំណុចនេះ ពីព្រោះនេះគឺជាការចូលរួមមកដ៏ធំ នៅក្នុងប្រព័ន្ធស៊ីវិលឡូ ។ ពីព្រោះនៅក្នុងអំឡុងពេលមួយឆ្នាំពេញយើងអាចមានលទ្ធភាពមាននៅការតទល់មុខគ្នានៅចំពោះសហចៅក្រមស៊ើបអង្កេតសម្រាប់មេធាវីការពារក្តីយើងនេះ ។ ហើយបន្ទាប់ពីមានការស៊ើបអង្កេតនុ៎ងរួចមក សហចៅក្រមស៊ើបអង្កេតទាំងពីរបានធ្វើនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយដែលខ្ញុំចង់យោងទៅលើ ឯកសារនុ៎ងឲ្យបានជាញឹកញាប់ ពីព្រោះគឺដីការបញ្ជូនរឿងទៅជំនុំជម្រះនេះហើយ លោកតុលាការ និងលោក លោកស្រីចៅក្រមទាំងអស់ ដែលលោក លោកស្រីត្រូវបានគេបញ្ជូនមក ។ លោក លោកស្រីបានទទួលនូវដីកាបញ្ជូនទៅជំនុំជម្រះនេះហើយមានន័យថា អង្គហេតុទាំងឡាយផ្សេងៗទៀតដែលបានបញ្ជូន និងបញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ មានន័យថាលោក លោកស្រី ចៅក្រម មានភារកិច្ចពិនិត្យមើលទៅលើដីកាបញ្ជូនរឿងឲ្យជំនុំជម្រះនោះ ។ ហើយទាក់ទងទៅនឹងអង្គហេតុទាំងអស់ គឺមានន័យតែអង្គហេតុទាំងអស់ដែលមាននៅក្នុងការពិភាក្សាដេញដោលនោះទេ ហើយដែលជាអង្គហេតុដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះនោះទេ ។ ដែលនេះ គឺជាលទ្ធផលនៃការស៊ើបអង្កេតហើយមានការចោទប្រកាន់បានធ្វើឡើងបន្ទាប់ពីមានការស៊ើបអង្កេត មកលើលោក កាំង ហ្កេកអ៊ាវ គឺជាការចោទប្រកាន់ ដែល

អាស្រ័យទៅលើអង្គហេតុដូចនេះ ថានៅក្នុងភ្នំពេញ និងក្នុងប្រទេសកម្ពុជាពីថ្ងៃទី១៧ មេសា ១៩៧៥ រហូតដល់ ៦ មករា ១៩៧៩ ។ ក្នុងនាមគាត់ជាអនុលេខា ឬក៏ជាលេខានៃស-២១ ហើយតាមរយៈសកម្មភាព និងអ្វីដែលគាត់មិនបានធ្វើនោះ គឺគាត់បង្ហាញអំពី ជាអ្នកធ្វើផែនការ រៀបចំគម្រោង ឬក៏បញ្ជា ឬក៏បានប្រព្រឹត្តិនូវឧក្រិដ្ឋកម្មដូចតទៅនេះ៖

[១៦:៣៨:៣៦]

គឺថាបានជួយ និងជំរុញ ឬមួយក៏ទទួលខុសត្រូវ ក្នុងនាមគាត់ជាមេរបស់ពួកគេ។ ហើយបន្ទាប់មកទៀត គឺមានការបង្ហាញនូវឧក្រិដ្ឋកម្មចំនួនពីរប្រភេទ៖ ទីមួយ គឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទីពីរ គឺបទល្មើសធ្ងន់ធ្ងរទៅលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ហើយដើម្បីកំណត់នូវសេចក្តីសន្និដ្ឋានទៅលើចំណុចអស់ទាំងនេះ ខ្ញុំចង់ឲ្យលោក លោកស្រីចៅក្រម ពិនិត្យទៅមើលទៅលើកថាខណ្ឌ១៣១ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះនោះ ដែលបញ្ជាក់យ៉ាងច្បាស់អំពីប្រភេទនៃបទល្មើសដែលត្រូវបានចោទប្រកាន់មកលើជនជាប់ចោទ ។

ប្រសិនបើសិនជាការធ្វើបទអន្តរាគមន៍របស់លោក ក្រេក អេតធេសាន់ ដើម្បីផ្តល់ទិដ្ឋភាពរួមអំពីរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងអំឡុងពេលនោះ បាទ, ពិតណាស់ នោះគឺជាចំណុចសំខាន់ ។ ហើយខ្ញុំបាននិយាយជាច្រើនដងមកហើយថា របាយការណ៍របស់លោក ក្រេក អេតធេសាន់ គឺជាធាតុផ្សំមួយដ៏សំខាន់ និងគួរឲ្យចាប់អារម្មណ៍បំផុតសម្រាប់គ្រប់ៗគ្នា ។ ហើយខ្ញុំចង់មានបំណងប្រាថ្នាចង់ឲ្យធ្វើការបោះពុម្ពផ្សាយរបាយការណ៍នេះឲ្យបានកាន់តែឆាប់នៅលើវេបសាយរបស់ អ.វ.ត.ក នៅពេលដែលរបាយការណ៍នោះ ត្រូវបានពិនិត្យ ពិចារណាបានត្រឹមត្រូវនៅក្នុងដំណើរនីតិវិធីនេះ ពីព្រោះអី ខ្ញុំចង់ឲ្យរបាយការណ៍នុ៎ង ត្រូវបានដឹងឮជាសាធារណៈ ។ ប៉ុន្តែ ថាតើយើង តើយើងគួរតែត្រូវដឹងតាមរយៈសេចក្តីសង្ខេបក៏ដោយ នៃឯកសារទាំងអស់ដែលលោក ក្រេក អេតធេសាន់ បានផ្អែកលើដើម្បីធ្វើរបាយការណ៍របស់គាត់នោះ នៅក្នុងច្បាប់ ខំមិនឡ ពិតហើយយើងត្រូវការ ។ ក៏ប៉ុន្តែ នៅក្នុងប្រព័ន្ធស៊ីវិលឡូវិញ ចំណុចនេះមិនជាការចាំបាច់ទេ ។ ហើយខ្ញុំចង់និយាយបញ្ជាក់ឲ្យច្បាស់បំផុតនៅក្នុងប្រព័ន្ធស៊ីវិលឡូ នេះមិនមែនចំណុចចាំបាច់ទេ ។ នៅក្នុងប្រព័ន្ធស៊ីវិលឡូ ដើម្បីធ្វើការបង្កើតចំណុចអស់ទាំងនេះ គឺមិនមែនជាការចាំបាច់ក្នុងការផ្តល់ឯកសារយោង ហើយនឹងអាន ទោះបីតាមរយៈសេចក្តីសង្ខេបក៏ដោយ នូវឯកសារទាំងអស់ដែលអ្នកជំនាញអាស្រ័យ ឬក៏ពឹងផ្អែកលើនោះ ។ នេះមិនមែនជាចំណុចចាំបាច់ទេ ។

ដូច្នេះ ហើយ ខ្ញុំចង់និយាយថា នីតិវិធីនៅថ្ងៃនេះ គឺជាការអានដ៏ទូលំទូលាយធំ ឬក៏អានទាំងអស់នូវឯកសារយោងផ្សេងៗ ដែលលោក ក្រេក អេតឆេសាន់ បានប្រើ គឺជាការខាតពេលវេលាសម្រាប់អង្គសវនាការតែប៉ុណ្ណោះ ។ ខ្ញុំមិនចង់និយាយទេ ប៉ុន្តែមានន័យថា ដូចជាយើងយកលុយទៅបោះបង់ចោលអ៊ីចឹង ហើយជាការខាតបង់ពេលវេលា ។ ខ្ញុំសូមនិយាយម្តងទៀត ជាការខាតបង់ពេលវេលាសម្រាប់ជនរងគ្រោះផងដែរ ។ ដូច្នេះគឺថា ខ្ញុំនុ៎ងចង់ដឹងឮថា តើលោក ក្រេក អេតឆេសាន់ ចង់និយាយអ្វីដែលជាចំណុចជាខ្លឹមសារសំខាន់នោះ ហើយខ្ញុំនឹងមានសំណួរដើម្បីសួរទៅលើគាត់ ហើយប្រសិនបើខ្ញុំធ្វើការតវ៉ានូវចំណុចខ្លះៗនៅក្នុងរបាយការណ៍របស់គាត់ នៅក្នុងការវិភាគដេញដោលគ្នានោះ មានន័យថាមុនពេលដែលគាត់ចង់យោងទៅលើឯកសារមួយ ឬក៏ឯកសារពីរ ឬក៏បីនោះ គឺគាត់នឹងអាចលើកយោងបាន ។ ក៏ប៉ុន្តែ បើសិនជាយើងធ្វើការអានជាប្រព័ន្ធនូវសេចក្តីសង្ខេបនៃឯកសារទាំងអស់ ដែលគាត់ពឹងផ្អែក ឬក៏អាស្រ័យលើជាមូលដ្ឋាននោះ ខ្ញុំចង់និយាយម្តងទៀតថា នេះគឺជាចំណុចខាតប្រយោជន៍ទាំងអស់នៅក្នុងប្រព័ន្ធស៊ីវិលឡូ ហើយខ្ញុំចង់ធ្វើការរំឮកដល់លោក លោកស្រីចៅក្រមផងដែរទាក់ទងទៅនឹងវិធានផ្ទៃក្នុងដែលបានចែងថា ចៅក្រមនឹងចេញសេចក្តីសម្រេចរបស់គាត់ ដោយធ្វើការជឿជាក់ទាំងស្រុងទៅលើភស្តុតាង ។ នេះជាអ្វីដែលខ្ញុំចង់និយាយ ហើយខ្ញុំចង់ឲ្យលោកស្រីជាថ្មីម្តងទៀត ពិនិត្យមើលទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលខាងសហចៅក្រមស៊ើបអង្កេតបានចេញ ហើយខ្ញុំក៏សូមធ្វើសេចក្តីសន្និដ្ឋានទៅលោក លោកស្រីចៅក្រមផងដែរថា រយៈពេលមួយឆ្នាំកន្លះ ដែលយើងបានធ្វើទៅលើសំណុំរឿងនេះ គឺថានឹងមិនជាការខាតបង់ពេលវេលាទេ ហើយនៅទីបំផុត គឺថាយើងមានន័យថាចង់ឲ្យតុលាការ មន្ត្រីតុលាការនុ៎ង យល់ឃើញថា ការចោទប្រកាន់ទៅលើជនជាប់ចោទនុ៎ង មានកម្រិតប៉ុនណា ហើយនិងអាចទទួលបានឬ ក៏អត់ទេ?

ដូច្នេះហើយ តើយើងគួរតែធ្វើអ្វីនៅពេលនេះ? ថាតើយើងចង់ឲ្យសាធារណមតិ សាធារណជនស្តាប់យើង ឬក៏យ៉ាងម៉េច? ឬមួយក៏ចង់និយាយអំពីទស្សនៈទានអំពីរបបខ្មែរក្រហមទាំងស្រុង នៅពេលនោះ ឬមួយក៏យើងចង់ធ្វើការពិភាក្សាដោយគ្មានអត្ថប្រយោជន៍អ្វីបន្តិចសោះ ដែលនេះគឺចំណុចដែលយើងមិនគួរធ្វើនោះ ។ បាទនេះ គឺជាសេចក្តីសន្និដ្ឋាន ដែលខ្ញុំបានធ្វើជូនចំពោះលោក ។

សូមអរគុណលោកប្រធាន ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:៤៦:៣៦]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះយើងដល់ពេលត្រូវសម្រាកហើយ ហើយក៏មានសភាពតឹងតែងដែរ លើការជជែកពិភាក្សាលើទម្រង់នៃនីតិវិធីប្រព្រឹត្តទៅនេះ ។ អ៊ីចឹង អង្គជំនុំជម្រះសាលាដំបូងប្រកាសផ្អាកសវនាការ

សម្រាប់សវនាការថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែក ចាប់ពីម៉ោងប្រាំបួនព្រឹកទៅ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ ទៅកាន់មន្ទីរឃុំឃាំងវិញ ។

អរគុណលោកបណ្ឌិត ក្រេក អេតឆេសាន់ ហើយអង្គជំនុំជម្រះសូមអញ្ជើញលោកមកផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតចាប់ពីម៉ោងប្រាំបួនព្រឹក ។ ហើយជម្រាបជូនដល់ភាគី ក៏ដូច្នេះដែរ សូមអញ្ជើញមកកាន់ សាលសវនាការឲ្យបានមុនម៉ោងប្រាំបួនព្រឹក ដើម្បីបន្តនីតិវិធីសវនាការ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:៤៨នាទី]*